គឹម-សែត

# ពលរដ្ឋវិជ្ជា

INSTRUCTION CIVIQUE

កម្មវិធីថ្មី - ថ្នាក់ឧត្តមដ្ឋាន



301

បណ្ណាគារខ្មែរសម័យ - កំពង់ចាម

301
ARCHIVES NATIONALES
COTE B-142-1736

គីម-សេត

# សឃ្ដីមវិជ្ជា

## សម្រាប់ថ្នាក់ឧត្ដមដ្ឋាន នៃបឋមភូមិ បំពេញវិជ្ជា

សៀវភៅនេះបានរៀបរៀង
ត្រឹមត្រូវតាមកម្មវិធីថ្មីផ្លូវការ

បណ្ណាគារខ្មែរសម័យ-កំពង់ចាម

ផ្ទះលេខ ៨ វិថីព្រះកេតុមាលា - កំពង់ចាម

រក្សាសិទ្ធិ

# សេចក្តីណែនាំ

នៅថ្នាក់ឧត្តមដ្ឋាន , មេរៀនស្តីអំពីសង្គមវិជ្ជាត្រូវតែបានច្បាស់លាស់ហើយអនុវត្តផង ។ គេត្រូវតែក្រសោបយកនូវសញ្ញាណណាដែលជ្រៅជ្រះ ហើយអធិប្បាយវែកញែកយ៉ាងល្អិតល្អន់ - រៀបចំដឹកនាំក្មេងតម្រូវក្នុងជីវភាពសង្គម ។ យ៉ាងនេះអាចនាំឲ្យក្មេងស្គាល់ដល់របៀប ទឹងមធ្យោបាយខាងរដ្ឋបាលនឹងនយោបាយនៃប្រទេសរបស់វា , ស្គាល់សិទ្ធិទឹងករណីយកិច្ចពលរដ្ឋខ្មែរ ។

នៅសាលារៀន , គ្រូត្រូវត្រៀមឱកាសដឹកនាំសិស្សឲ្យប្រតិបត្តិនូវសញ្ញាណដែលបានសិក្សាទាំងប៉ុន្មាន ។

# កម្មវិធីថ្មីផ្លូវការ សង្គមរាស្ត្រ

## ត្រីមាសទី ១

(ខែកញ្ញា - តុលា - វិច្ឆិកា - ធ្នូ)

– សញ្ញាណសង្ខេបទាក់ទងទៅលើការបោះឆ្នោត

ក–) លក្ខណៈទាំងឡាយដែលអាចជ្រើសតាំងបាន

ខ–) សម្លេងក្នុងការបោះឆ្នោត

គ–) ពេលបោះឆ្នោត

ឃ–) បញ្ជីបោះឆ្នោត

ង–) ប័ណ្ណបោះឆ្នោត

ច–) ការិយាល័យបោះឆ្នោត

ឆ–) ហិបឆ្នោត

ជ–) ការបោះឆ្នោត. ។

– ការចាំបាច់នៃការបញ្ចេញមតិនិងរបៀបបញ្ចេញមតិ ។

– គោលការណ៍ចម្បងនៃលទ្ធិប្រជាធិបតេយ្យៈ ការបែងចែកនូវអំណាចក្នុងរដ្ឋ ។

ក –) រដ្ឋសភា ៖

១- សភាប្រជារាស្ត្រនិងសភាក្រុង
២- ក្រុមប្រឹក្សាព្រះរាជអាណាចក្រ
៣- រដ្ឋសភាប្រៀបធៀបនឹងសភាប្រជារាស្ត្រ ។

ខ - ) រដ្ឋាភិបាល

គ - ) តុលាការ

## ត្រីមាសទី ២

( ខែមករា - កុម្ភៈ - មីនា )

- ក្រសួងយុត្តិធម៌ ៖

ក - ) សាលាលហុ

ខ - ) សាលាដំបូងឬសាលាលុះឃុន

គ - ) សាលាឧទ្ធរណ៍

ឃ - ) សាលាឧក្រិដ្ឋ

ង - ) សាលាវិនិច្ឆ័យ

- អង្គការសិក្សានៅប្រទេសកម្ពុជា ៖

ក - ) ការចាត់ចែងគ្រូគង្វាល

ខ - ) ថ្នាក់ផ្សេងៗនានាខាងសិក្សាធិការទូទៅ

គ - ) សិក្សាបច្ចេកទេស

- របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។

- គំនូរបំប្រួញអំពីអគ្គការរដ្ឋបាលនៃប្រទេសកម្ពុជា ។

- រដ្ឋធម្មនុញ ៖

    ក-) ប្រវត្តិនៃរដ្ឋធម្មនុញ្ញ

    ខ-) ការផ្លាស់ប្តូរកែប្រែថ្មី

    គ-) សញ្ញាណជាសារវន្តនៃរដ្ឋធម្មនុញ្ញ

## ត្រីមាសទី ៣

( ខែឧសភា - មិថុនា - កក្កដា )

- សម្បជញ្ញៈ នឹងឯកភាពនៃប្រជាជាតិ

- បំរើកផបល័ន្ក - ប្រជាជាតិនឹងប្រជាជន

- អគ្គការសហប្រជាជាតិ ( អ.ស.ប. )

    ក-) អង្គការអន្តរជាតិខាងការងារ (អ.អ ក )

    ខ-) អង្គការសហប្រជាជាតិសម្រាប់ការអប់រំវិទ្យាសាស្ត្រនឹងវប្បធម៌ (អ.ស.ប អ.វ.វ. )

    គ-) អង្គការពិភពលោកខាងសុខាភិបាល (អ.ព.សៈ)

    ឃ-) អង្គការសហប្រជាជាតិសម្រាប់ស្បៀងអាហារនឹងក្សេត្រកម្ម ( អ.ស.ប. ស.ក. )

    ង-) សហភាពប្រៃសណីយ៍ពិភពលោក (ស.ប.ព.)

    ច-) ញាណអន្តរជាតិជាកត្តាសន្តិភាពក្នុងពិភពលោក ។

– ការពារទំនាក់ទំនងផ្លូវទូតនឹងកុងស៊ុលនៃប្រទេសកម្ពុជា ជាមួយនឹងបរទេស ។

– ទូតបរទេសនៅអមព្រះរាជអាណាចក្រខ្មែរ ។

– គោលការណ៍អន្តរជាតិ ដើម្បីសន្តិភាពក្នុងសកលលោក ។

ភ្នំពេញ ថ្ងៃទី ១ មេសា ១៩៦០

គឹម-សែត

សង្គមវិជ្ជា

សម្រាប់ថ្នាក់ឧត្តមដ្ឋាននៃបឋមភូមិសិក្សា

## លក្ខណៈដែលអាចឈរឈ្មោះធ្វើបេក្ខជនបាន

### ឈរឈ្មោះធ្វើបេក្ខជនមេឃុំ

ឃុំថ្មី ត្រូវមានអ្នកមានសិទ្ធិបោះឆ្នោតទាំងប្រុសស្រី យ៉ាងតិចត្រឹមប្រាំមួយរយ ( ៦០០ ) នាក់ ក្នុងកាលបរិច្ឆេទបង្កើតឃុំ ។

អ្នកដែលមានសិទ្ធិបោះឆ្នោត ហើយដែលមានអាយុ ២៥ ឆ្នាំ នៅពេលបញ្ចប់បញ្ជីបោះឆ្នោត អាចឈរឈ្មោះធ្វើជាបេក្ខជនមេឃុំបាន កុំឲ្យតែមានចូលក្នុងបទបញ្ញត្តិ ដូចខាងក្រោមនេះ ៖

១ – ខ្លួនជាភ្នាក់ងារពេជការ, ទោះបីកំពុងធ្វើការ, ឈប់សំរាក ឬ ឈប់លំហែរ ក៏ដោយ ( ឈរឈ្មោះមិនបាន ) ។

២ – ខ្លួនជាអ្នកជំនួញដែលមានប្រកាសធនក្ស័យ ហើយដែល

គ្នា ដែលច្បាប់លុបលាងទោសឲ្យ ( ឲ្យឈរឈ្មោះមិនបាន ) ។

៣ – ខ្លួនជាជនវិកលចរិត , ល្ងីល្ងើ ( ឈរឈ្មោះមិនបាន ) ។

៤ – ខ្លួនធ្លាប់ធ្វើមេឃុំ , ធ្វើជំទប់ ឬ មន្ត្រីសាធារណៈហើយ ដែលគេបានបញ្ឈប់ពីមុខតំណែង ឬ ហូតងារតាមវិធានការនៃវិន័យក្នុងរយៈ ៥ ឆ្នាំ គិតតាំងពីកាលបរិច្ឆេទឈប់កាន់មុខតំណែង ( ឈរឈ្មោះមិនបាន ) ។

៥ – ខ្លួនជាអ្នកមានទោសគុកព្យួរជាបទទោសមជ្ឈិម ក្នុងរយៈពេលដែលព្យួរទោស ( ឈរឈ្មោះមិនបាន ) ។

៦ – ខ្លួនជាជនបរទេស ទើបតែសុំចូលជាតិខ្មែរ មានរយៈពេលតិចជាង ១០ ឆ្នាំ ( ឈរឈ្មោះមិនបាន ) ។

៧ – ខ្លួនជាខ្មែរប៉ុន្តែខ្លួនបានចូលជាតិដទៃកាលពីឆ្នាំមុន , ឥឡូវខ្លួនលាជាតិវិញ ( ចូលមកជាតិដើមវិញ ) មានរយៈពេលតិចជាង ៥ ឆ្នាំ ( ឈរឈ្មោះមិនបាន ) ។

៨ – ខ្លួនធ្លាប់បានប្រឡងប្រជែង ធ្លាក់ពីបេក្ខជនភាពនៃសភា-ខេត្ត ក្នុងសម័យបោះឆ្នោតលើកមុន ( ឈរឈ្មោះមិនបាន )

៩ - ខ្លួនជាមនុស្ស ១ រូបដែលរាជការខេត្តយល់ឃើញថា មិនស្មោះត្រង់នឹងរាជការ ( ឈរឈ្មោះមិនបាន ) ។

ក្រៅអំពីជនចូលមកឈរឈ្មោះធ្វើបេក្ខជន , លោកមេឃុំចាស់ និងក្រុមជំនុំឃុំ អាចឈរឈ្មោះជាបេក្ខជនឡើងវិញបានទៀត ។

អំពីពាក្យបណ្ដឹង . -

ពាក្យបណ្ដឹងសុំឈរឈ្មោះធ្វើបេក្ខជនមេឃុំ ត្រូវជូនទៅចៅហ្វាយស្រុក ៤៥ ថ្ងៃយ៉ាងយឺត មុនថ្ងៃបោះឆ្នោត ។

កាលបរិច្ឆេទនៃការបោះឆ្នោត

លោកចៅហ្វាយខេត្ត ត្រូវកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតរើសមេឃុំ តាមដីកាខេត្ត ដែលបោះពុម្ពផ្សាយនិងបិទនៅទីប្រជុំខេត្ត - ស្រុក - ឃុំ និងតាមវត្តអារាម យ៉ាងតិច២ខែមុនថ្ងៃបោះឆ្នោត ។

កាលបរិច្ឆេទបើកសម័យឃោសនា

លោកចៅហ្វាយខេត្តត្រូវបញ្ជាក់អំពីកាលបរិច្ឆេទបើកសម័យ

ឃោសនាបោះឆ្នោត ,   ដែលត្រូវបើកឲ្យធ្វើ ១៥ ថ្ងៃមុនពេល

បោះឆ្នោត ។

ថ្ងៃបោះឆ្នោត

ថ្ងៃបោះឆ្នោតរើសមេឃុំ ត្រូវយកថ្ងៃអាទិត្យណាមួយ ។

ការិយាល័យបោះឆ្នោត

ការិយាល័យមួយ   សម្រាប់អ្នកមានសិទ្ធិបោះឆ្នោតយ៉ាង

ច្រើនត្រឹម ៥០០ នាក់ ។

ការបោះឆ្នោត

ការបោះឆ្នោតត្រូវបោះតាំងបញ្ជីដែលបេក្ខជនម្នាក់ ៗ បាន

កាយឈ្មោះបេក្ខជនក្រុមជំនុំរបស់ខ្លួន នឹងឈ្មោះខ្លួន ព្រមទាំង

មានរូបថតរបស់ខ្លួន ដែលមានទំហំ ៤ ស.ម. × ៦ ស.ម. ។

ការជាប់ឆ្នោត

បញ្ជីរបស់បេក្ខជនណា   ដែលបានឆ្នោតគាំគច្រើនជាង

គេ ត្រូវទុកជាជាប់ឆ្នោត ។

អាណត្តិមេឃុំ

មេឃុំនឹងក្រុមជំនុំ ក្រោយដែលបានជាប់ឆ្នោតហើយ អាចចូលទៅធ្វើការក្នុងសាលាឃុំបាន ៤ ឆ្នាំ ។

# ឈរឈ្មោះធ្វើបេក្ខជនតំណាងរាស្ត្រ

អ្នកតំណាងរាស្ត្រទាំងឡាយ ត្រូវជ្រើសតាំងឡើងដោយប្រជាជនទាំងពួងបោះឆ្នោតសកលផ្ទាល់, ជាសម្ងាត់ ។

ចំនួនអ្នកតំណាងរាស្ត្រដែលត្រូវជ្រើសតាំងនោះ ត្រូវរើសយក ១ រូបក្នុងជនជាតិខ្មែរបីម៉ឺន ( ៣០.០០០ ) នាក់ ដែលមានចុះឈ្មោះក្នុងបញ្ជី ។ បើមានភាគជននេះលើសពីមួយម៉ឺនប្រាំពាន់ ( ១៥.០០០ ) នាក់ ត្រូវទុកដូចជាបីម៉ឺននាក់ ( ៣០.០០០ ) ដែរ ; ប៉ុន្តែសម្រាប់ក្រុងភ្នំពេញ ចំនួនអ្នកតំណាងរាស្ត្រត្រូវមានពីរ (២) រូបយ៉ាងតិច ។

## អ្នកដែលមានសិទ្ធិឈរឈ្មោះធ្វើបេក្ខជនតំណាងរាស្ត្រ

បាននោះ គឺពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំគត់ ត្រឹមថ្ងៃបើកសម័យបោះឆ្នោត ហើយដែលមានលក្ខណសម្បត្តិដូចខាងក្រោមនេះ ៖

១ – មិនដែលមានសាលក្រមកាត់ទោស

– – – – – – – – – – –

ក )- បើមានសាលក្រមខាងបទឧក្រិដ្ឋ , គ្មានសិទ្ធិបោះឆ្នោតអស់ ១ ជីវិត

ខ )- បើមានសាលក្រមកាត់ទោសដាក់គុកពី ១ ឆ្នាំឡើងទៅ ត្រូវបាត់សិទ្ធិបោះឆ្នោតក្នុងរយៈ ១០ ឆ្នាំ ( គិតតាំងពីថ្ងៃផុតទោស ) ។

គ )- បើមានសាលក្រមកាត់ទោសដាក់គុកពី ១ ខែទៅទល់នឹង ១ ឆ្នាំ ត្រូវបាត់សិទ្ធិបោះឆ្នោត ៥ ឆ្នាំ ។

ឃ )- បើមានសាលក្រមកាត់សេចក្ដីដាក់បរិវាកនុទោស ត្រូវបាត់សិទ្ធិបោះឆ្នោតក្នុងកំឡុងពេលដែលដកសិទ្ធិជាពលរដ្ឋ ។

ង )- បើមានសាលក្រមកាត់ទោសដោយដាច់ណាត់ ជាមជ្ឈិមទោសឬជាលហុទោស , ត្រូវបាត់សិទ្ធិបោះឆ្នោតក្នុងកំណត់ពេលដែលមានទោសនោះ ។

២ - មិនដែលមានសាលក្រមកាត់ទោស អំពីបទធនក្ស័យតាមធម្មតា ឬដោយទុច្ចរិត បើខ្លួនជាអ្នកជំនួញ ។

ក) – បើមានសាលក្រមនេះ ត្រូវបាត់សិទ្ធិបោះឆ្នោតក្នុងរវាងបី (៣) ឆ្នាំ ។

៣ – មិនដែលមានទណ្ឌកម្មត្រូវហូតង៉ារ - ទោះបីទណ្ឌកម្មក្នុងបទវិន័យតិចតួចយ៉ាងណាក្តី, បើខ្លួនជាមន្ត្រីរាជការ ។

១ - ) បើមានការហូតង៉ារនេះត្រូវបាត់សិទ្ធិបោះឆ្នោតរវាងបី (៣) ឆ្នាំ ។

៤ – មិនដែលមានសាលក្រមកាត់ទោសដោយបាត់ខ្លួន ។

៥ – មិនវិកលចរិត, ល្ងីល្ងើ ។

៦ – មិនត្រូវគេបង្ខាំងខ្លួន (កំពុងជាប់ឃុំឃាំងឬនិរទេស) ។

៧ – ដែលបានសញ្ជាតិជាខ្មែរ ដោយតាមទារជាតិ ឬដោយចូលជាតិច្រើនជាងដប់ (១០) ឆ្នាំ ។

ដើម្បីឲ្យទទួលជាបេក្ខភាពបាន លុះត្រាតែបានបង់ប្រាក់ធានានៅទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួនប្រាំរយរៀល (៥០០៛០០) ទុកជាមុន ។ ប្រាក់ធានានេះត្រូវអូសយកជាប្រ-យោជន៍ថវិកាជាតិ បើកាលណាបេក្ខជនបានចំនួនឆ្នោត ពុំគ្រប់

– – – – – – – – – – – – – –

ភាគមួយក្នុងបួន (១/៤) នៃចំនួនឆ្នោត ដែលបានបោះតាំងប៉ុន្មាននោះ ។

មេឃុំទាំងឡាយអាចឈរឈ្មោះ ជាបេក្ខជនតំណាងស្រុក ឲ្យគេជ្រើសតាំងក្នុងមណ្ឌលបោះឆ្នោត ដែលមានឃុំរបស់ខ្លួននោះបាន តែត្រូវឲ្យលាឈប់ពីមុខងារខ្លួនជាមុនសិន ។

## អំពីពាក្យបណ្ដឹង

បេក្ខជនទីមួយៗ ត្រូវធ្វើពាក្យសុំឈរឈ្មោះមួយច្បាប់ដែលមានចុះហត្ថលេខារបស់ខ្លួន ហើយមានពាក្យសេចក្ដីថា៖ ខ្លួនឈរឈ្មោះក្នុងមណ្ឌលណា ខ្លួនជាសមាជិកគណបក្សនយោបាយណា ឬក៏ជាអ្នកមិនមានទាក់ទិនក្នុងបក្សពួកអ្វីទេ ( Elément saint de la population ) ។ ពាក្យសុំឈរឈ្មោះនេះត្រូវជូនទៅទីស្ដីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាមួយសញ្ញាប័ត្រកំណើត ១ ច្បាប់, សំបុត្រថ្កោលទោសចច្បាប់នឹងវិញ្ញាបនប័ត្រសំគាល់ថាមានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត ព្រមទាំងបង្កាន់ដៃបង់ប្រាក់ធានា (៥០០រ) បើយ៉ាងយូរត្រឹមដប់ (១០) ថ្ងៃក្រោយថ្ងៃបើក

សម័យឃោសនាបោះឆ្នោត ។

ចំពោះជនណាដែលទាមទារជាតិខ្មែរ ឬចូលជាតិខ្មែរ ត្រូវបង្ហាញសាលក្រម ឬព្រះរាជក្រិត្យ ដែលអនុញ្ញាតសញ្ជាតិជាខ្មែរនោះ ជូនជាប់ទៅជាមួយថែមទៀតផង ។

បេក្ខជនណាដែលជាអ្នករាជការ មិនចាំបាច់ជូនសេចក្តីស្រង់សំបុត្រកំណើត និងសំបុត្រថ្កោលទោសទេ ។

កត់បំណាំ

បេក្ខជនតំណាងកស្រុកមួយ ៗ ត្រូវប្រកាន់ទីលំនៅមួយនៅក្រុងភ្នំពេញដោយខានពុំបាន ក្នុងរវាងយ៉ាងតិចបំផុតត្រឹមសម័យឃោសនាបោះឆ្នោតព្រោះអីដំណឹង ឬ បង្អាប់ផ្សេង ៗ អំពីការបោះឆ្នោតនោះនឹងបញ្ជូនទៅឲ្យសាមីខ្លួនដល់ទីលំនៅ ទើបទុកជាបានការ ។

## កាលបរិច្ឆេទបើកសម័យឃោសនា

លោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងអំពីការកំណត់កាលបរិច្ឆេទ បើកសម័យឃោសនា តាមសេចក្តីប្រកាស

របស់ខ្លួន ។

សម័យបោះឆ្នោត ត្រូវបើកឡើងក្នុងកំណត់ពីរ (២) ខែ យ៉ាងយូរ ក្រោយថ្ងៃដែលផុតនីតិកាលនិមួយ ៗ (រដ្ឋសភា) ។

ថ្ងៃបោះឆ្នោតត្រូវធ្វើក្រោយ ថ្ងៃបើកសម័យឃោសនាយ៉ាងយូរប្រាំបី (៨) សប្តាហ៍ (អាទិត្យ) ។

ថ្ងៃបោះឆ្នោត

ថ្ងៃបោះឆ្នោតត្រូវរើសយកតែថ្ងៃអាទិត្យជាដរាប ។ ការបោះឆ្នោតត្រូវចាប់ផ្តើមធ្វើពីម៉ោងប្រាំពីរ (៧) ព្រឹករហូតដល់ម៉ោងដប់ប្រាំពីរ (១៧) គឺម៉ោង ៥ ល្ងាច ។

ការិយាល័យបោះឆ្នោត

ក្នុងការិយាល័យបោះឆ្នោត ត្រូវមានក្រុមអភិបាលបោះឆ្នោតមួយ ក្នុងចំនួនអ្នកបោះឆ្នោតប្រាំមួយរយ (៦០០) នាក់ ។

ការិយាល័យបោះឆ្នោតត្រូវមានធ្វើពលតែឃុំ ទីសង្កាត់ក្នុងក្រុង ។

ការបោះឆ្នោត

ការបោះឆ្នោតត្រូវចាប់ផ្ដើមធ្វើតាំងពីម៉ោងប្រាំពីរ រហូតដល់ម៉ោងដប់ប្រាំពីរ ។ ក្រោយពីម៉ោងដប់ប្រាំពីរនេះតទៅ មិនត្រូវទទួលឲ្យជនដែលមានចុះឈ្មោះក្នុងបញ្ជីណា ចូលទៅបោះឆ្នោតទៀតបានឡើយ ។

បញ្ជីរាយឈ្មោះ អ្នកបោះឆ្នោត ត្រូវដាក់ដំកល់នៅលើតុ ។ លុះដល់ពេលបោះឆ្នោត, អធិបតីក្រុមអភិបាលបោះឆ្នោតប្រកាសថាពេលបោះឆ្នោតបើកហើយ ។

អ្នកបោះឆ្នោតចូលម្នាក់ម្ដងទៅមុខតុ ដែលមានសន្លឹកឆ្នោត ហើយយកលិខិតសម្រាប់សំគាល់ខ្លួន បង្ហាញទៅអធិបតី ។ សមាជិកនៃក្រុមអភិបាលឆ្នោត ប្រគល់សន្លឹកឆ្នោតរបស់បេក្ខជនម្នាក់ ៗ មួយសន្លឹក ឲ្យទៅអ្នកបោះឆ្នោត ។ លុះបានសន្លឹកឆ្នោតនេះហើយ អ្នកបោះឆ្នោតក៏ចូលទៅក្នុងបន្ទប់កំបាំង ដើម្បីជ្រើសយកសន្លឹកឆ្នោតនៃបេក្ខជន ដែលខ្លួនចង់ជ្រើសតាំងនោះមកបត់ជាមួន ហើយកាន់នៅដៃម្ខាង ។ ដៃម្ខាងទៀតកាន់

សន្លឹកឆ្នោតឯទៀត ដែលឆ្នោតនិមួយៗត្រូវបត់ជាបួនដូចគ្នាដែរ ។

កាលបើបានចេញពីបន្ទប់កំបាំងមកហើយ អ្នកបោះឆ្នោតត្រូវចូលទៅចំពោះមុខអធិបតី ។ លុះបានបញ្ជាក់ឃើញច្បាស់ថាមានឈ្មោះជាអ្នកបោះឆ្នោតមែនហើយ អធិបតីក៏យកលិខិតសំគាល់ខ្លួនអ្នកបោះឆ្នោតនោះ មកចុះហត្ថលេខាតូចមួយជាចំណាំ រួចប្រគល់លិខិតនេះទៅឲ្យខ្លួនវិញ ទើបអនុញ្ញាតឲ្យបោះឆ្នោត ។

## ការជាប់ឆ្នោត

បេក្ខជនដែលបានភាគច្រើនជាងគេ ក្នុងចំនួនឆ្នោតដែលបានបោះដោយត្រឹមត្រូវនោះ ត្រូវទុកជាបានជ្រើសតាំង (ជាប់) បើមានបេក្ខជនច្រើននាក់បានទទួលឆ្នោតស្មើគ្នា ត្រូវយកអ្នកដែលមានអាយុច្រើនជាង ។

## អាណត្តិរបស់អ្នកតំណាងរាស្ត្រ

នីតិកាលរបស់រដ្ឋសភា មាន ៤ ឆ្នាំ ។ ប៉ុន្តែព្រះមហា

ក្សត្រទ្រង់រំលាយរដ្ឋសភាបាននៅពេលណា ដែលរដ្ឋសភាធ្វើការឱ្យខូចប្រយោជន៍ជាតិ ។

---

# ឈរឈ្មោះធ្វើបេក្ខជនក្រុមប្រឹក្សាព្រះរាជអាណាចក្រ

ក្រុមប្រឹក្សាព្រះរាជអាណាចក្រមានសមាសភាពដូចតទៅ ៖

- សមាជិកពីររូប ត្រូវបានព្រះមហាក្សត្រចាត់តាំង ។
- សមាជិកពីររូប ត្រូវបានរដ្ឋសភាជ្រើសតាំង ។
- សមាជិកប្រាំបីរូប ជាអ្នកតំណាងភូមិភាគ ត្រូវជ្រើសតាំងដោយបោះឆ្នោតអសាកលមិនចំពោះ ។
- សមាជិកប្រាំបីរូបទៀត ជាអ្នកតំណាងវិជ្ជាជីវៈផ្សេង ៗ ត្រូវបានជ្រើសតាំងដោយបោះឆ្នោតចំពោះ ។

បូករួមទាំងអស់ត្រូវជាម្ភៃ (២០) រូប ។

អាចសុំឈរឈ្មោះធ្វើបេក្ខជនក្រុមប្រឹក្សាព្រះរាជអាណាចក្របាន ជនខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិចត្រឹម៤០ឆ្នាំ ហើយដែលមានលក្ខណៈសម្បត្តិដូចខាងក្រោមនេះ ៖

១- មិនដែលមានសាលក្រមតុលាការកាត់ទោស ជាអជ្ញាគតិ ។

២- មិនដែលមានសាលក្រមកាត់ទោសអ៊ីអំពីបទជនក្បត់ ។

៣- មិនមែនកំពុងជាប់ឃុំឃាំង ។

៤- មិនដែលមានសាលក្រមកាត់ទោសដោយបាត់ខ្លួន ។

៥- មិនក្ខតលីលា ។

៦- មានសញ្ជាតិជាខ្មែរ ។

៧- ចូលជាតិខ្មែរបានចំនួនវេលាជាង ១០ ឆ្នាំ ។

ចំពោះបេក្ខជនតំណាងវិជ្ជាជីវៈផ្សេង ៗ ត្រូវមានលក្ខណៈសម្បត្តិខាងក្រោមនេះថែមទៀត ។

- ត្រូវឲ្យមានប៉ាតង់ បើខ្លួនជាអ្នកជំនួញ, ជាឧស្សាហករ ឬជាជនប្រកបវិជ្ជាជីវៈសេរី ។

- ត្រូវឲ្យមានស្រែយ៉ាងតិចប្រាំហិកតារ ( ៥.០០០០ម.២ ) បើខ្លួនជាអ្នកធ្វើស្រែ ។

- ត្រូវមានដីចំការយ៉ាងតិចមួយហិកតារ ( ១.០០១០ម.២ )

បើខ្លួនជាកសិករទើទៃពីអ្នកដាំស្រូវ ។

## អំពីពាក្យបណ្ដឹង

បេក្ខជនទីប្រឹក្សាព្រះរាជអាណាចក្រ តំណាងភូមិភាគ, តំណាងវិជ្ជាជីវៈផ្សេង ៗ ហើយនឹងតំណាងអ្នករាជការត្រូវធ្វើពាក្យសុំឈរឈ្មោះ ជូនទៅលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃយ៉ាងយឺតណាស់ត្រឹមហាសិបប្រាំ (៥៥) ថ្ងៃ មុនថ្ងៃបោះឆ្នោត ក្នុងពាក្យសុំនោះត្រូវចុះហត្ថលេខាហើយបញ្ជាក់ថា :

- ចង់តំណាងភូមិភាគណា ?
- ចង់តំណាងវិជ្ជាជីវៈណា ?
- ចង់តំណាងអ្នករាជការក្រុមណា ?
- ខ្លួនជាសមាជិកនៃគណបក្សនយោបាយណា ?
- ឬក៏អត់មានចូលក្នុងចលនានយោបាយឯណាមួយទេ ?

ពាក្យដែលធ្វើនេះទៀតត្រូវផ្ញើជាប់ជាមួយនឹង ៖

១ –ព្រឹត្តិប័ត្រកំណើត ១ សន្លឹក

២ – សំបុត្រថ្កោលទោស ១ សន្លឹក

៣ - សេចក្ដីចម្លងព្រះរាជក្រឹត្យ ដែលអនុញ្ញាតឲ្យខ្លួនចូលជាតិខ្មែរ១សន្លឹក (ចំពោះតែអ្នកចូលជាតិ) ។

៤ - បង្កាន់ដៃបង់ប្រាក់ប្រចាំ (៥០០រៀល) នៅក្រសួងមហាផ្ទៃ ។

សម័យបោះឆ្នោត

សម័យបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាព្រះរាជអាណាចក្រមានរយៈពេលស្មើគ្នា ទីងរយៈពេលនៃសម័យបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រដែរ ។

ថ្ងៃបោះឆ្នោត

ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យ បន្ទាប់ពីថ្ងៃអាទិត្យដែលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ការជាប់ឆ្នោត

បេក្ខជនដែលទទួលសន្លឹកឆ្នោតច្រើនជាងគេ ដោយរបៀបត្រូវបានជាប់ឆ្នោត ។

# លក្ខណៈសម្បត្តិដែលគួរបោះឆ្នោតឲ្យ

នៅពេលបោះឆ្នោតម្តង ៗ ទោះបីបោះឆ្នោតរើសមេឃុំ បោះឆ្នោតរើសតំណាងរាស្ត្រ ឬ បោះឆ្នោតរើសក្រុមប្រឹក្សាព្រះរាជអាណាចក្រ, អ្នកដែលបោះឆ្នោតត្រូវបោះឆ្នោតឲ្យតែបេក្ខជនណាដែលមានលក្ខណៈសម្បត្តិល្អដូចតទៅនេះ ៖

- បេក្ខជននោះប្រកបដោយលក្ខណៈ ៤ :
  - កតញ្ញូ
  - តស៊ូ
  - ខន្តី
  - ក្លាហាន ។
- បញ្ហាផ្ទាល់ខ្លួន: មិនស្មោកគ្រោក
- បញ្ហាគ្រួសារ: ជាមេគ្រួសារដ៏ថ្លៃថ្នូរ
- បញ្ហាសង្គម: មានគំនិតចង់ឲ្យប្រទេសជាតិមានវឌ្ឍនភាព

ហ៊ានឆាប់រហ័សដោយប្រកបនូវទស្សនៈនិយមភ្លឺស្វាង

- ទស្សនៈជីវិត ឬជីវទស្សន៍
- ទស្សនៈមនុញ្ញផល
- ទស្សនៈសង្គមជាតិ ។

អ្នកបោះឆ្នោតត្រូវគិតថា៖ ជីវិតខ្លួនឯងគ្រួសារខ្លួនបានសុខសាន្ត ឬបានក្តីក្តៅក្រហាយអាស្រ័យលើសន្លឹកឆ្នោតដែលខ្លួនបោះចូលក្នុងហិបឆ្នោតនោះឯង ។

## អំពីហិបឆ្នោត

មុននឹងបើកឱកាសបោះឆ្នោត អធិបតីនៃក្រុមអភិបាលបោះឆ្នោតត្រូវបើកហិបឆ្នោតបង្ហាញអ្នកជំនួយ ទាំងជនណាដែលចង់មើល ឲ្យឃើញថាហិបនោះទទេស្អាត ។ រួចត្រូវចាក់សោបិទ ហើយដាក់ហិបនោះនៅលើតុឲ្យគេមើលឃើញដោយងាយ ។ ឯកូនសោត្រូវដកចេញពីមេ ហើយដាក់នៅជិតហិបឆ្នោត ។

## អំពីសន្លឹកឆ្នោត

សន្លឹកឆ្នោតត្រូវធ្វើដោយក្រដាសសសុទ្ធមានទទឹង ៦ សង់ទីម៉ែត្រ,បណ្តោយ ៩ សង់ទីម៉ែត្រ ( ៦×៩ ) ។ នៅខាងមុខសន្លឹកឆ្នោតត្រូវឲ្យបោះពុម្ព ៖

១ – សញ្ញាសំគាល់របស់បេក្ខជន

២ – នាមត្រកូលនិងនាមខ្លួនបេក្ខជន នៅខាងក្រោមសញ្ញាខ្លួន ។

នៅខាងខ្នងសន្លឹកឆ្នោតត្រូវទុកឲ្យស្អាត មិនត្រូវមានចុះសញ្ញាអ្វីជាសំគាល់ឡើយ ។

សន្លឹកឆ្នោតត្រូវក្រសួងមហាផ្ទៃចាត់ចែងបោះពុម្ព ប៉ុន្តែបេក្ខជនត្រូវចេញថ្លៃឲ្យពេញពុម្ព ។ ( សន្លឹកឆ្នោតដែលយើងនិយាយខាងលើនេះ សម្រាប់ការជ្រើសតាំងតំណាងរាស្ត្រ និងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ) ។

ចំពោះសន្លឹកឆ្នោតដែលបោះជ្រើសតាំងមេឃុំវិញគេហៅថា

«បញ្ជី» ។ បញ្ជីនេះត្រូវមានលក្ខណៈដូចតទៅ ៖

– ធ្វើដោយក្រដាសសមានទំហំប៉ុនៗគ្នា ។

– នៅខាងក្នុងបញ្ជីត្រូវមានរូបថតបេក្ខជនមេឃុំទំហំ៤×៦។

– មានចុះនាម-គោត្តនាមនៃបេក្ខជនមេឃុំ ដែលជាមេបញ្ជី ហើយនឹងមាន គោត្តនាមរបស់បេក្ខជនក្រុមជំនុំទាំងអស់ ។

នៅទំព័របញ្ជីខាងខ្នងទៀត មិនត្រូវមានចុះសេចក្តីអ្វីឡើយ ។

## ការចាំបាច់នៃការបញ្ចេញមតិ

ប្រទេសកម្ពុជាយើង កាន់លទ្ធិប្រជាធិបតេយ្យ ។ លទ្ធិប្រជាធិបតេយ្យនេះ ជាបំណងលទ្ធិមួយ ដែលលើកស្ត្រីឲ្យធ្វើជាធំ, គឺរាស្ត្រមានអំណាចក្នុងការចាត់ចែងកិច្ចការរដ្ឋ ឲ្យបានចំរើន ។ រដ្ឋសភាជាមន្ទីរធ្វើការរបស់តំណាងរាស្ត្រ ។ តំណាងរាស្ត្រជាអ្នកតែងច្បាប់ការពារនឹងលើកតំកើងជីវភាពរាស្ត្រ ។ តំណាងរាស្ត្រហ្នឹង, មានឋានៈខ្ពង់ខ្ពស់ហ្នឹង ក៏ដោយសាតែរាស្ត្របោះឆ្នោតឲ្យដែរ ។ ហេតុហ្នឹងហើយ ការបញ្ចេញ

មតិ ក្នុងពេលបោះឆ្នោត ជាករណីយកិច្ចរបស់កស្ត្រព្រោះជាជីវិតរបស់កស្ត្រ ៗ កស្ត្រមិនត្រូវធ្វេសប្រហែសទេ ៗ ត្រូវតែនាំគ្នាទៅបញ្ចេញមតិ, ទៅបោះឆ្នោត ដោយសតិសម្បជញ្ញៈគឺការគ្រាក់រឭកដោយខ្លួនឯង ព្រោះអនាគតនៃជីវិតខ្លួនស្ថិតនៅលើការបញ្ចេញមតិ, ការបោះឆ្នោតនោះហើយ ៗ

## អំពីអង្គការនីតិបញ្ញត្តិ-រដ្ឋសភា

រដ្ឋសភាជាអ្នកកាន់អំណាចនីតិបញ្ញត្តិ ដែលជាកម្លាំងទី ១ របស់រដ្ឋ ៗ អំណាចនីតិបញ្ញត្តិ គឺអំណាចតែងតាំងច្បាប់សម្រាប់ឲ្យគណៈរដ្ឋមន្ត្រី-និងតុលាការប្រតិបត្តិតាមដោយត្រឹមត្រូវ ដើម្បីសេចក្ដីសុខសប្បាយចំរើនរុងរឿងនិងយុត្តិធម៌របស់ប្រជាជាតិ និងមាតុប្រទេស ៗ អស់លោកតំណាងកស្ត្រ ចូលទៅធ្វើការក្នុងរដ្ឋសភា ជាអ្នកតំណាងរបស់ប្រជាជាតិទាំងមូល ៗ តាមគោលការណ៍, ក្នុងចំនួនពលរដ្ឋខ្មែរ ៣០.០០០ នាក់ ដែលមានអាយុ ២០ ឆ្នាំឡើងទៅ ត្រូវមានអ្នកតំណាងមួយរូប ៗ អ្នក

តំណាងរាស្ត្រត្រូវមានអាយុ ២៥ ឆ្នាំយ៉ាងតិច ។ នីតិកាលរបស់អ្នកតំណាងរាស្ត្រខ្មែរយើងបានកំរិតត្រឹម ៤ ឆ្នាំ ។ ក្នុងសមាជិកភាពនៃរដ្ឋសភានេះ អ្នកតំណាងរាស្ត្រមិនអាចត្រូវគេចោទប្រកាន់រកខុស ចាប់ខ្លួនឃុំឃាំង ឬ យកទៅជំនុំជំរះឡើយ ។ គេអាចនាំយករូបអ្នកតំណាងរាស្ត្រឯណាមួយ ទៅឲ្យតុលាការជំនុំជំរះបាន លុះត្រាតែរដ្ឋសភាបានប្រជុំសមាជិកទាំងអស់ បោះឆ្នោតបញ្ចេញមតិដកអភ័យឯកសិទ្ធិពីតំណាងរាស្ត្ររូបនោះចេញហើយសិន ។

រដ្ឋសភាមានសម័យប្រជុំសាមញ្ញយ៉ាងតិច ២ ដងក្នុង ១ ឆ្នាំ ។ សម័យប្រជុំនីមួយ ៗ មានកំណត់យ៉ាងតិចត្រឹម ៣ ខែ ។

រដ្ឋសភាជាអ្នកអនុញ្ញាត ឬមិនអនុញ្ញាតឲ្យគណៈរដ្ឋមន្ត្រីនេះ ឬគណៈរដ្ឋមន្ត្រីនោះធ្វើការ ។ គឺថាៈ រាជរដ្ឋាភិបាលកើតឡើងអំពីរដ្ឋសភា បើរដ្ឋសភាពិនិត្យឃើញថាៈ រាជរដ្ឋាភិបាល មិនគោរពតាមច្បាប់ដែលរដ្ឋសភាបានតែងឲ្យយកទៅប្រើនោះទេ, ឬក៏រាជរដ្ឋាភិបាលធ្វើឲ្យខូចប្រយោជន៍ជាតិ, រដ្ឋសភានឹងរំលាយរាជរដ្ឋាភិបាលនោះចោលភ្លាម ។

# របៀបជ្រើសតាំងតំណាងរាស្ត្រ

ការជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើដោយវិធីបោះឆ្នោតសម្ងាត់ជាសកល។ ក្នុងសម័យបោះឆ្នោតនោះមានបេក្ខជនស្រី-ប្រុសជាច្រើនឈរឈ្មោះឲ្យគេជ្រើសតាំង ។ ប្រុសនិងស្ត្រីខ្មែរទាំងឡាយមានសិទ្ធិបោះឆ្នោតឲ្យបេក្ខជនណាមួយដែលខ្លួនគាប់ចិត្ត។ អធិបតេយ្យនៃបណ្ដាជនទាំងឡាយ នឹងអាចប្រព្រឹត្តទៅបានដោយសារការជ្រើសតាំងអ្នកតំណាងរាស្ត្រនេះ ដ្បិតអ្នកតំណាងនេះហើយ ដែលជាអ្នកសម្រេចការផ្សេង ៗ នឹងចាត់ចែងកិច្ចការនានាក្នុងការគ្រប់គ្រងប្រទេសព្រមទាំងជាអ្នកតែងច្បាប់ ក្នុងនាមនៃបណ្ដាជនផង ។

ហេតុនេះ, ពលរដ្ឋម្នាក់ ៗ មានករណីយកិច្ចនឹងជ្រើសតាំងអ្នកតំណាងខ្លួនឲ្យត្រឹមត្រូវ គឺថាជ្រើសតាំងដោយឥតទាក់ទិននឹងលាភផ្សេង ៗ ( កុំស៊ីសំណូកបេក្ខជន ) ។

ត្រូវបោះឆ្នោតឲ្យបេក្ខជន ឬបេក្ខជនទីណាដែលខ្លួនជឿជាក់ថា: មានសម្បទាគ្រប់គ្រាន់ នឹងចូលទៅរដ្ឋសភា ធ្វើការឲ្យ

ប្រទេសជាតិបានចំរើនឿនលឿនទៅមុខបាន ។

# អំពីសភាប្រជារាស្ត្រប្រចាំខេត្ត និងប្រចាំព្រះរាជធានី

ក្រៅអំពីរដ្ឋសភាដែលមានទីតាំងនៅឯភ្នំពេញ, យើងមានសភាមួយទៀត ហៅថាសភាប្រជារាស្ត្រប្រចាំខេត្តនិងប្រចាំព្រះរាជធានី ។

សមាជិកនៃសភានេះ ជាអ្នកតំណាងស្រុកនីមួយ ៗ ក្នុងខេត្ត និងជាអ្នកតំណាងសង្កាត់នីមួយ ៗ ក្នុងព្រះរាជធានី ។ រដ្ឋធម្មនុញ្ញ (១៩៥៥) បង្កើតឲ្យមានសភាប្រជារាស្ត្រនេះ ដើម្បីឲ្យការត្រួតត្រារបស់ប្រជាជនលើរាជរដ្ឋាភិបាល បានជិតដល់ថែមទៀត ។

សមាជិកនៃសភាប្រជារាស្ត្រ ត្រូវជ្រើសតាំងតាមវិធីបោះឆ្នោតសកលដោយចំពោះ ។

អ្នកដែលមានសិទ្ធិបោះឆ្នោតនោះ គឺពលរដ្ឋខ្មែរទាំងពីរប្រភេទ ដែលមានអាយុយ៉ាងតិច ២០ ឆ្នាំ ។

សភាប្រជាពលរដ្ឋត្រូវប្រជុំនៅទីប្រជុំខេត្ត ឬ នៅរាជធានីក្នុងមន្ទីរមួយដែលបានរៀបចំការ ។ សមាជិកសភាប្រជាពលរដ្ឋត្រូវជ្រើសតាំងសម្រាប់ ២ ឆ្នាំ ។ សភាប្រជាពលរដ្ឋមានភារៈបញ្ចេញមតិ, ជូនយោបល់ចំពោះការអនុមតិនៃថវិកាជាតិ, ចំពោះបញ្ជីស្រង់ប្រាក់ចំណូលចំណាយផ្ទាល់ឆ្នាំ, ចំពោះសេចក្ដីព្រាងកិច្ចចងការប្រាក់នៃរាជរដ្ឋាភិបាល ។

(នៅពេលដែលយើងសរសេរសៀវភៅនេះ, សភាប្រជាពលរដ្ឋបានផ្អាកសកម្មភាពសិន តាមមតិរបស់សមាជជាតិ) ។

## អំពីក្រុមប្រឹក្សាព្រះរាជអាណាចក្រ

ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ជាសភាមួយធ្វើការអមសភាប្រជាជាតិ (រដ្ឋសភា) ក្នុងកិច្ចបង្កើតច្បាប់ថ្មីសម្រាប់នគរ ។ ក្រុមនេះមានភារៈខាងឲ្យយោបល់ ក្នុងការសម្រេចច្បាប់នីមួយ ១

ប៉ុន្តែគ្មានសិទ្ធិបញ្ចេញមតិតាំងច្បាប់ទេ ។ គណៈរដ្ឋមន្ត្រីមិនទទួលខុសត្រូវចំពោះក្រុមប្រឹក្សាព្រះរាជអាណាចក្រឡើយ ។ សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រខ្លះត្រូវចាត់តាំង ខ្លះត្រូវជ្រើសតាំងដោយបោះឆ្នោតអសាកល ។ និងឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាព្រះរាជអាណាចក្របានត្រូវមានអាយុយ៉ាងតិចត្រឹម៤០ឆ្នាំ ។

អាណត្តិនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រមាន ៤ ឆ្នាំ ដូចសភាប្រជាជាតិដែរ ។ ក្រុមប្រឹក្សាព្រះរាជអាណាចក្រនេះជាសភាចាស់ទុំ មានការពិសោធន៍និងមានការវាងវៃច្រើន ។ នៅប្រទេសខ្លះដូចជាប្រទេសបារាំងជាដើម គេហៅក្រុមនេះថា: ព្រឹទ្ធសភា (Sénat) ។

# រដ្ឋសភាប្រៀបធៀប នឹង សភាប្រជារាស្ត្រ

សភាប្រជារាស្ត្រទុកដូចជាប្អូនរបស់រដ្ឋសភា ។ សមាជិកនៃរដ្ឋសភាជាតំណាងប្រជាជាតិទាំងមូល ។ សមាជិកនៃសភាប្រជារាស្ត្រជាតំណាងរបស់ស្រុកក្នុងខេត្តនីមួយ ៗ ជាតំណាងសង្កាត់ក្នុងរាជធានី ។ រដ្ឋសភាជាអ្នកតែងច្បាប់ នឹងជាអ្នកពិនិត្យតាមដានមើលសកម្មភាពរបស់រាជរដ្ឋាភិបាល ។ សភាប្រជារាស្ត្រមានសិទ្ធិនឹងធ្វើញត្តិជូនដល់រដ្ឋសភាឬ រដ្ឋាភិបាលអំពីការចាត់ចែងនៃរាជការសាធារណៈក្នុងផែនការជាតិ ។ សភានេះត្រូវតាមពិនិត្យមើលរាជការចាត់ចែងការសាធារណៈក្នុងខេត្តឬរាជធានី ។ សភាប្រជារាស្ត្រ ត្រូវមានសិទ្ធិសួរដេញដោលអ្នករាជការនានា ។ បើសភាប្រជារាស្ត្របានបញ្ចេញមតិក្នុងបីភាគបួន នៃចំនួនសមាជិកមិនទុកចិត្តលើចៅហ្វាយខេត្ត - ចៅហ្វាយក្រុងឬចាងហ្វាងសាលា

ជំហូន ' កុនផែនចំណុះរបស់ខ្លួន សេចក្ដីសំរេចនេះត្រូវបញ្ជូនទៅក្រុមប្រឹក្សាព្រះរាជអាណាចក្រពិនិត្យថែមទៀត ។

សមាជិកសភាប្រជារាស្ត្រ ត្រូវជ្រើសតាំងសម្រាប់ពីរ(២)ឆ្នាំ មិនមែនបួន (៤) ឆ្នាំដូចអ្នកតំណាងរាស្ត្រទេ ។ កំណត់ពេលនេះ នឹងបដិសេធចោលមុនបាន ដូចជាអ្នកតំណាងរាស្ត្រដែរ ។

## អំពីអង្គការនីតិប្បតិបត្តិ

អង្គការនីតិប្បតិបត្តិជាអង្គការ ទី ២ របស់រដ្ឋដែលកាន់លទ្ធិប្រជាធិបតេយ្យ ។ អង្គការនេះមានភារៈទទួលច្បាប់ទាំងឡាយដែលរដ្ឋសភាធ្វើឲ្យយកទៅអនុវត្តរៀងរាល់ថ្ងៃ ដើម្បីឲ្យបានសុខសាន្តក្នុងប្រទេសជាតិ, ឲ្យប្រជាជនមានជីវភាពថ្កុំថ្កើងរុងរឿង និងឲ្យមានមិត្តភាពយ៉ាងត្រជាក់ត្រជុំជាមួយនឹងបរជាតិទូទៅ ។ អង្គការនីតិប្បតិបត្តិគ្មានអំណាចប្រព្រឹត្តបទអ្វីដែលរដ្ឋសភាមិនអនុញ្ញាតឲ្យប្រព្រឹត្តនោះទេ ប៉ុន្តែអង្គការនេះមានសិទ្ធិក្នុងការស្នើសុំរដ្ឋសភាឲ្យតែងជាច្បាប់នេះ ឬច្បាប់នោះដែរ ។ បើរដ្ឋសភាពុំព្រមធ្វើឲ្យទេ ខ្លួនគ្មានអំណាចធ្វើនីតិប្បតិបត្តិដោយអត្តានុមតិឡើយ ។

— អ្នកណាជានាយកក្នុងអង្គការនីតិប្បតិបត្តិនេះ ? - គឺលោកនាយករដ្ឋមន្ត្រី ។ ដូច្នេះ គឺរដ្ឋាភិបាលនេះហើយដែលជាអ្នកកាន់អំណាចនីតិប្បតិបត្តិ ។

# អំពីរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល គឺរដ្ឋាភិបាលរបស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង (ប្រទេសដែលមានព្រះមហាក្សត្រសោយរាជ្យ គេហៅថា «រាជរដ្ឋាភិបាល»; ប្រទេសដែលជាសាធារណរដ្ឋ ( République ) គេហៅថា «រដ្ឋាភិបាលនៃសាធារណរដ្ឋ Gouvernement de la république» ។ ក្នុងរដ្ឋាភិបាលនីមួយ ៗ មានលោករដ្ឋមន្ត្រី, លោករដ្ឋលេខាធិការជាច្រើនរួមប្រជុំគ្នា ជាសមាសភាពមួយ ដែលគេហៅថា: គណៈរដ្ឋមន្ត្រី ក្នុងគណៈរដ្ឋមន្ត្រីនេះ មានលោកនាយកមួយរូប ហៅថា: នាយករដ្ឋមន្ត្រី ។ ក្នុងសមាសភាពនៃគណៈរដ្ឋមន្ត្រី គេច្រើនឃើញមាន៖

១ – ទេសរដ្ឋមន្ត្រី ( Ministre d'Etat )

២ – រដ្ឋមន្ត្រី (Ministre )

៣– រដ្ឋលេខាធិការ ( Secrétaire d'Etat )

ចំណែកអនុរដ្ឋលេខាធិការ (Sous Secrétaire d'Etat) គ្មានសំឡេងក្នុងគណៈរដ្ឋមន្ត្រីទេ ។ លោកនាយករដ្ឋមន្ត្រីមានឋានៈតូចជាងលោកប្រធានរដ្ឋសភា ។

ក្នុងរដ្ឋាភិបាលនីមួយៗ គេឃើញមានរដ្ឋមន្ត្រីកាន់កាប់គ្រប់ក្រសួងទាំងអស់ ។

១ – នាយករដ្ឋមន្ត្រី ( Président du Conseil des Ministres )

២ – រដ្ឋមន្ត្រីមហាផ្ទៃ ( Ministre de l'Intérieur )

៣ – រដ្ឋមន្ត្រីការពារប្រទេស (Ministre de la défense nationale)

៤ – រដ្ឋមន្ត្រីការបរទេស (Ministre des affaires étrangères )

៥ – រដ្ឋមន្ត្រីអប់រំជាតិ (Ministre de l'Education nationale )

៦ – រដ្ឋមន្ត្រីសាធារណៈសុខាភិបាល ( Ministre de la santé publique )

៧ – រដ្ឋមន្ត្រីយុត្តិធម៌ ( Ministre de la justice)

៨ – រដ្ឋមន្ត្រីសាធារណៈការនិងទូរគមនាគមន៍(Ministre des travaux publics et des télécommunications )

៩ – រដ្ឋមន្ត្រីថវិកាជាតិ ( Ministre du budget national )

១០ – រដ្ឋមន្ត្រីហិរញ្ញវត្ថុ (Ministre des Finances)

១១ – រដ្ឋមន្ត្រីពាណិជ្ជកម្មនិងឧស្សាហកម្ម (Ministre du Commerce et de l'industrie)

១២ – រដ្ឋមន្ត្រីឃោសនាការ (Ministre de l'Information)

១៣ – រដ្ឋមន្ត្រីវប្បធម៌ (Ministre de la culture)

១៤ – រដ្ឋមន្ត្រីការពារលើផ្ទៃប្រទេសនិងនគរបាល (Ministre de la défense en surface et de la police nationale)

១៥ – រដ្ឋមន្ត្រីទេសចរណ៍ (Ministre de Tourisme-)

១៦ – រដ្ឋមន្ត្រីសង្គមកិច្ចនិងកិច្ចការអ្នកស្រែចំការ (Ministre de l'action sociale et des affaires paysannes)

១៧ – រដ្ឋមន្ត្រីកសិកម្ម (Ministre de l'agriculture)

១៨ – រដ្ឋមន្ត្រីផែនការ (Ministre du Plan)

១៩ – រដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ (Ministre de l'Economie nationale)

ទីធ្វើការរបស់លោកនាយករដ្ឋមន្ត្រី គេហៅថា: នាយក

រដ្ឋមន្ត្រីស្ថាន ឬ ទីស្តីការនាយករដ្ឋមន្ត្រី ( Présidence du Conseil des Ministres ) ទីដែលរដ្ឋមន្ត្រីដទៃទៀតធ្វើការ គេហៅថា: រដ្ឋមន្ត្រីស្ថាន ( Ministère... ) ។ គណៈរដ្ឋមន្ត្រីត្រូវប្រជុំគ្នាក្នុង ១ អាទិត្យម្តង ។ លោកអគ្គលេខាធិការនៃគណៈរដ្ឋមន្ត្រី ( le Secrétaire général du Conseil des Ministres ) ធ្វើសេចក្តីកត់ហេតុក្នុងពេលប្រជុំម្តង ៗ ។

## ការតែងតាំងរាជរដ្ឋាភិបាល

រដ្ឋាភិបាលជាអ្នកកាន់អំណាចនីតិប្រតិបត្តិ គឺជាអ្នកអនុវត្តច្បាប់ដែលសភាប្រជាជាតិ ( Assemblée nationale ) បានបង្កើត ។ ក្នុងរដ្ឋាភិបាលមាននាយកមួយរូបហៅថា: នាយករដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រីទី ១ ។

លោកប្រធានរដ្ឋសភា និង ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្របានទូលស្នើដល់ព្រះករុណា នូវនាមរបស់ជនទាំងឡាយណា ដែលគួរឲ្យឡើងធ្វើជានាយករដ្ឋមន្ត្រីបាន ។ កាលបើ

បាននូវរបស់នាមវរជនទាំងនោះ ព្រមទាំងបានព្រះពិចារណារួចហើយ ព្រះមហាក្សត្រក៏ទ្រង់ព្រះរាជានុញ្ញាតឲ្យវរជនមួយរូបចូលមកក្រាបបង្គំគាល់ - ព្រះអង្គក៏តែងតាំងឲ្យវរជននោះធ្វើជានាយករដ្ឋមន្ត្រី ។ លោកនាយករដ្ឋមន្ត្រីដែលទើបនឹងបានព្រះ-មហាក្សត្រតែងតាំងនោះ ដើរទៅជ្រើសរើសវរជនជាច្រើនរូបទៀត ដែលខ្លួនគាប់ចិត្ត ឲ្យចូលមកធ្វើការក្នុងរដ្ឋាភិបាលរបស់ខ្លួន ។ កាលបើជ្រើសរើសបានគ្រប់ចំនួនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញហើយ, លោកនាយកត្រូវនាំគណៈរដ្ឋមន្ត្រីរបស់ខ្លួនទៅសុំសេចក្ដីទុកចិត្តអំពីរដ្ឋសភា ។ នៅក្នុងរដ្ឋសភានោះ លោកនាយករដ្ឋមន្ត្រី ត្រូវអានបុរេអធិប្បាយរៀករៀបយ៉ាងល្អិតល្អន់នូវផែនការដែលរដ្ឋាភិបាលខ្លួនត្រូវធ្វើ ( ផែនការនយោបាយ - សេដ្ឋកិច្ច-វប្បធម៌ ។ល។ ) កាលបើរដ្ឋសភាបានប្រគល់សេចក្ដីទុកចិត្តជូនមកខ្លួននឹងគណៈរដ្ឋមន្ត្រីរបស់ខ្លួន ។ ក្រោយអំពីនេះ លោកនាយកត្រូវបង្ហាញជូនដល់អស់លោកតំណាងរាស្ត្រ នូវរូបនឹងនាមត្រកូល ព្រមទាំងមុខងារ របស់រដ្ឋមន្ត្រីនិមួយ ៗ ផង ។

អស់លោកតំណាងរាស្ត្រ, ក្រោយអំពីការសាកសួរដេញដោលលោកនាយករដ្ឋមន្ត្រីថ្មីហើយ កំចាប់ផ្ដើមបោះឆ្នោតបញ្ចេញមតិភ្លាម ៗ បើអស់លោកតំណាងរាស្ត្រភាគច្រើន មិនពេញចិត្តនឹងគណៈរដ្ឋមន្ត្រីនេះទេ, នោះ, លោកនាយកត្រូវទៅគាល់ព្រះមហាក្សត្រ សុំព្រះរាជានុញ្ញាតលាលែងវិញ ៗ ព្រះមហាក្សត្រក៏ទ្រង់ព្រះរាជបញ្ជាឲ្យលោកប្រធានរដ្ឋសភា ទូលស្នើឈ្មោះបេក្ខជននាយករដ្ឋមន្ត្រីថ្មីទៀត ៗ

កាលបើអស់លោកតំណាងរាស្ត្រ បញ្ចេញមតិទុកចិត្តលើគណៈរដ្ឋមន្ត្រីថ្មីហើយ, ព្រះករុណាក៏ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីថ្មីនោះភ្លាម ៗ រដ្ឋកិច្ចាលថ្មី ក៏ចាប់ផ្ដើមធ្វើការភ្លាមទៅ ៗ គណៈរដ្ឋមន្ត្រីត្រូវទទួលការខុសត្រូវរួមគ្នាចំពោះរដ្ឋសភាអំពីកិច្ចនយោបាយទូទៅ ៗ ហេតុនេះចំពោះរឿងនយោបាយ រដ្ឋមន្ត្រីមួយរូប ៗ មិនអាចហ៊ានការគាត់ដោយខ្លួនឯងបានឡើយ ត្រូវតែប្រជុំគណៈរដ្ឋមន្ត្រីសិន ៗ ក្នុងទីប្រជុំគណៈរដ្ឋមន្ត្រីនោះ មានតែលោករដ្ឋលេខាធិការទេ ដែលអាច

បញ្ចេញសំឡេងបាន ។ អនុវត្តលេខាធិការ ឥតមានអំណាចបញ្ចេញសំឡេងឡើយ ។

## នាយករដ្ឋមន្ត្រីស្ថាន

មន្ទីរដែលលោកនាយករដ្ឋមន្ត្រីធ្វើការ ហៅថា: នាយករដ្ឋមន្ត្រីស្ថាន (Présidence du Conseil des Ministres) ។ នាយករដ្ឋមន្ត្រីស្ថាន តាំងនៅក្រុងភ្នំពេញដែលជាធានីនយោបាយនិងពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា ។ មុខងាររបស់លោកនាយករដ្ឋមន្ត្រី គឺគិតខាងនយោបាយទូទៅ (នយោបាយខាងក្នុងនិងខាងក្រៅប្រទេស) ហើយនិងត្រួតមើលចលនាឬសកម្មភាពទាំងឡាយរបស់សមាជិកទាំងអស់នៃរដ្ឋាភិបាលរបស់ខ្លួន-តើប្រព្រឹត្តទៅបានផលបែបណាខ្លះ មានការចំរើនជឿនលឿនឬក៏ថយក្រោយ ។ លោកនាយករដ្ឋមន្ត្រី ត្រូវតែណែនាំគណៈរដ្ឋមន្ត្រីឲ្យប្រតិបត្តិយ៉ាងហ្មត់ចត់ និងឲ្យមានការវិវឌ្ឍន៍ឆាប់រហ័សតាមគម្រោងការដែលខ្លួនបានសន្យាចំពោះមុខអ្នកតំណាងរាស្ត្រក្នុងរដ្ឋសភា កាល

មុនដែលខ្លួនបានទទួលសេចក្ដីទុកចិត្តអំពីរដ្ឋសភា ។ លោកនាយករដ្ឋមន្ត្រីជារដ្ឋបុរសទទួលខុសត្រូវចំពោះជាតិ ។

## រដ្ឋមន្ត្រីស្ថាន នៃ ក្រសួងមហាផ្ទៃ

រដ្ឋមន្ត្រីស្ថាននៃក្រសួងមហាផ្ទៃតាំងនៅរាជធានីភ្នំពេញដែរ ។ លោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានការៈរៀបចំស្រុកទេសឲ្យបានសុខសាន្តនិងចំរើន ។ ដើម្បីឲ្យក្រសួងមហាផ្ទៃមានសកម្មភាពល្អ ក្រសួងនេះត្រូវមានក្រុមព្រះនគរបាល និងក្រុមការពារលើផ្ទៃប្រទេសជួយធ្វើការ ។ ពន្ធនាគារក៏ជាផ្នែកមួយរបស់ក្រសួងមហាផ្ទៃដែរ សម្រាប់ទទួលមនុស្សទុច្ចរិតយកទៅអប់រំបំពត់ចរិយាឲ្យបានត្រឹមត្រូវឡើងវិញ សមជាមនុស្សថ្មីថ្មរទៅអនាគត ។

## រដ្ឋមន្ត្រីស្ថាន នៃ កិច្ចការបរទេស

រឿងរ៉ាវដែលទាក់ទងនឹងប្រទេសក្រៅ គឺជាការៈផ្ទាល់របស់លោករដ្ឋមន្ត្រីក្រសួងកិច្ចការបរទេស ។ ឧបមាថា: បើមានការ

តំណាងមួយចំពោះប្រទេសដទៃ លោករដ្ឋមន្ត្រីនៃកិច្ចការបរទេសនេះ ចេញមុខតំណាងនាមនៃរាជការរដ្ឋាភិបាលខ្មែរ ។ ទូតបរទេសទាំងឡាយដែលមកធ្វើការក្នុងប្រទេសខ្មែរ គ្មានសិទ្ធិទៅទាក់ទងផ្ទាល់នឹងលោកនាយករដ្ឋមន្ត្រីខ្មែរទេ ត្រូវតែទៅទាក់ទងនឹងលោករដ្ឋមន្ត្រីកិច្ចការបរទេស រួចលោករដ្ឋមន្ត្រីកិច្ចការបរទេសយករឿងនោះមកជំរាបដល់លោកនាយកនៃរាជរដ្ឋាភិបាលខ្មែរ ។

រដ្ឋមន្ត្រីស្ថានកិច្ចការបរទេស ជាអ្នកចុះហត្ថលេខាលើលិខិតឆ្លងដែន (Passe-port) ។

## រដ្ឋមន្ត្រីស្ថាន នៃ ក្រសួងការពារជាតិ

ក្រសួងការពារជាតិ ជារបងរបស់ជាតិ ។ ជាតិទុកដូចជាផ្ទះ, កងយោធាទុកដូចជារបង ។ បើរបងមាំហើយ សត្រូវខាងក្រៅមិនហ៊ានចូលមកបំផ្លាញផ្ទះយើងបានទេ ។

លោករដ្ឋមន្ត្រីក្រសួងការពារជាតិ មានមុខងារការពារជាតិកុំឲ្យសត្រូវចូលមកលុកលុយ ។ កាលពីដើមក្រសួងការពារជាតិ

នេះ គេហៅថា: ក្រសួងសង្គ្រាម (Ministère de Ia Guerre) ។

ក្នុងកិច្ចចាត់ចែងការពារជាតិនេះ រដ្ឋនិមួយៗ សុទ្ធតែមានអគ្គសេនា-ធិការយោធពលមួយ នៅក្រោមកិច្ចបញ្ជាការរបស់លោកបញ្ជាការម្នាក់ ។ ខ្មែរយើងមានអគ្គសេនាធិការយោធពលខេមរភូមិន្ទ (E M.G. des F.A.R.K) ដែលមានលោកឧត្តមសេនីយម្នាក់ជាអគ្គបញ្ជាការ ។ មានសេនាធិការខាងកងទ័ពអាកាស , កងទ័ពដីគោក នឹង កងទ័ពសមុទ្រ នៅដោយឡែកៗពីគ្នាទៀត ។ សេនាធិការនិមួយ ៗ មានមេបញ្ជាការមួយ ។ ក្នុងអគ្គសេនាធិការយោធពលខេមរៈភូមិន្ទ មានការិយាល័យ ៦ ចាត់ចែងការផ្សេងៗ អំពីគ្នា ។

ក្នុងកងទ័ពនិមួយ ៗ មាន ៖

- នាយទាហាន
- នាយទាហានរង
- នឹងពលទាហាន ,

ដែលមានសក្តិខុសតាមដូចតទៅនេះ ៖

- សេនាប្រមុខ
- ឧត្តមសេនីយឯក
- ឧត្តមសេនីយទោ
- ឧត្តមសេនីយត្រី

- វរៈសេនីយឯក
- វរៈសេនីយទោ
- វរៈសេនីយត្រី

- អនុសេនីយឯក
- អនុសេនីយទោ
- អនុសេនីយត្រី

- នាយចំណាន់
- ព្រឹន្ទបាលឯក
- ព្រឹន្ទបាល

- ពលបាលឯក
- ពលបាល
- ពលឯក
- ពលទោ
- ពលទាហាន ។

នៅប្រទេសខ្មែរយើង មានសាលាហ្វឹកហ្វឺនទាហានយ៉ាង ហ្មត់ចត់ប្រាកដប្រជាណាស់ គឺសាលាបង្ហាត់ពលទាហាន, សាលាបង្ហាត់នាយទាហានរង, សាលាបង្ហាត់នាយទាហាន និង ពដសការយោធពលខេមរភូមិន្ទ (Accadémie royale militaire Khmère )

## រដ្ឋមន្ត្រីស្ថាន នៃ ការអប់រំជាតិ

ក្រសួងអប់រំជាតិជាក្រសួងមួយសម្រាប់ផ្តល់វប្បធម៌ (La culture) ដល់ពលរដ្ឋទាំងអស់ ។ រដ្ឋមន្ត្រីស្ថាននៃការអប់រំជាតិតាំងនៅ ក្រងក្នុំពេញ ។

. លោករដ្ឋមន្ត្រីអប់រំជាតិ កាន់កាប់ក្រសួងនេះជាមួយនឹងចាងហ្វាងនៃសិក្សាធិការជាតិ (Directeur général de l'Instruction publique) លោកចាងហ្វាងឧត្តមសិក្សានឹងមធ្យមសិក្សា Directeur de l'Enseignement supérieur et Secondaire) ហើយនឹងលោកអធិការនាយកនៃបឋមសិក្សា ( Inspecteur en Chef de l'Enseignement primaire ) ។

ការសិក្សាក្នុងខេត្ត ស្ថិតនៅក្រោមកិច្ចត្រួតត្រារបស់លោកអធិការមួយរូប (Inspecteur primaire provincial. ) ។

មន្ត្រីតាំងឡាយក្នុងក្រសួងអប់រំជាតិគឺ ៖

– រដ្ឋមន្ត្រីអប់រំជាតិ

– ចាងហ្វាងនៃសិក្សាធិការជាតិ

– ចាងហ្វាងនៃឧត្តមនឹងមធ្យមសិក្សាជាតិ

– អធិការនាយកបឋមសិក្សា

– អធិការប្រចាំខេត្ត

– នាយកតំបន់សិក្សា

– គ្រូឧបរស

- សិក្សាគិរកេស្ស
- ពាន់ហ្វានអនុវិទ្យាល័យ
- សាលាធិការ
- សាស្ត្រាចារ្យ
- គ្រូបង្រៀន
- គ្រូបង្រៀនជំនួយ
- គ្រូបង្ហាត់ ៗ

នៅប្រទេសខ្មែរយើង ក្នុងផ្នែកអប់រំជាតិនេះមានក្រុមពិសេសមួយទៀត គឺក្រុមអប់រំមូលដ្ឋានជាតិ ដែលមានការៈយ៉ាងធ្ងន់ក្នុងកិច្ចប្រជាសិក្សា ៗ ក្រុមនេះ មិនត្រឹមតែបង្រៀនវិជ្ជាអក្សរដល់ប្រជាជនប៉ុណ្ណោះទេ គេបានណែនាំប្រជាជនឲ្យគ្រេបជញ្ចក់វិជ្ជាគ្រប់បែបយ៉ាងដោយផ្ទាល់ដៃគេ ហើយដោយឲ្យប្រជាជនអនុវត្តតាម ៗ ផង ដូចជាការសង់ផ្ទះ, ការដាំដំណាំ, ការដាំស្ល, ការសំអាត, ការថែរក្សាគោក្របី នឹងការចិញ្ចឹមបុត្រធីតាជាដើម ៗ លោកម៉ែន - ឈុំជានាយកនៃក្រុមអប់រំមូលដ្ឋានជាតិ

នេះ (Education de base) ។

អំពីភូមិសិក្សានៅប្រទេសខ្មែរ

ភូមិសិក្សានៅប្រទេសខ្មែរយើង ចែកចេញជាបីភូមិ៖

១ - បឋមភូមិសិក្សា

– ថ្នាក់កុមារដ្ឋាន

– ថ្នាក់បរិវឌ្ឍណដ្ឋាន

– ថ្នាក់អាទិកដ្ឋាន

– ថ្នាក់មធ្យមដ្ឋានទី ១

– ថ្នាក់មធ្យមដ្ឋានទី ២

– ថ្នាក់ឧត្តមដ្ឋាន

– ( ថ្នាក់ឧត្តមដ្ឋានពិសេស ) ។

២ - មធ្យមភូមិសិក្សា

– ថ្នាក់ទី ៦ ទំនើប

– ថ្នាក់ទី ៥ ទំនើប

– ថ្នាក់ទី ៤ ទំនើប

– ថ្នាក់ទី ៣ ទំនើប ( ប្រឡងសញ្ញាប័ត្រ - ឌីប្លូម )

— ថ្នាក់ទី ២ ទំនើប

— ថ្នាក់ទី ១ ទំនើប ( ប្រឡងឲមធ្យមសិក្សាប័ត្រ ទី ១ )

— ថ្នាក់បញ្ចប់វិជ្ជា ( Classe terminale )

៣ – ឧត្តមភូមិសិក្សា

ឧត្តមភូមិសិក្សា គឺការសិក្សាវិជ្ជាដោយផ្នែក ៗ ដាច់អំពីគ្នា ៗ សាលាដ៏ធំនេះ គេហៅថា " មហាវិទ្យាល័យ-Université „ ។

ខ្មែរយើងមានមហាវិទ្យាល័យហើយ ដែលសព្វថ្ងៃនេះមានសាខាដូចតទៅ ៖

— ឧត្តមវិទ្យាល័យ ( Faculté ) ខាងអក្សរសាស្ត្រ

— ឧត្តមវិទ្យាល័យខាងវិទ្យាសាស្ត្រ

— ឧត្តមវិទ្យាល័យខាងធម្មសាស្ត្រ ( ច្បាប់ - សេដ្ឋកិច្ច - និងនយោបាយ ) "

- ឧត្តមវិទ្យាល័យខាងវេជ្ជវិទ្យា

- សាលាភូមិន្ទរដ្ឋបាល

- វិជ្ជាស្ថានជាតិគរុកោសល្យ ។

តុះទៅថ្ងៃមុខ ,  ប្រទេសយើង  នឹងមានឧត្តមសក្ដាគ្រប់ផ្នែកវិជ្ជាទាំងអស់ដូចជានៅប្រទេសមហាអំណាចទាំងឡាយជាមិត្តដែរ ។

## រដ្ឋមន្ត្រីស្ថាន នៃ សាធារណៈសុខាភិបាល

ដើម្បីព្យាបាលសុខភាព នឹងកំចាត់រោគាព្យាធិចេញពីរាងកាយប្រជារាស្ត្រ ,  រាជរដ្ឋាភិបាលប្រគល់ភារៈនេះទៅឲ្យក្រសួងមួយហៅថា: ក្រសួងសាធារណៈសុខាភិបាល ។ ក្រសួងនេះមានលោករដ្ឋមន្ត្រីសាធារណៈសុខាភិបាលជានាយក ( Ministre de la santé publique ) ។ លោករដ្ឋមន្ត្រីចាត់ចែងកិច្ចការសព្វសារពើ ជាមួយនឹងលោកគ្រូពេទ្យទាំងឡាយ ។ នៅក្នុងក្រុងភ្នំពេញ , នៅគ្រប់ខេត្ត នឹងគ្រប់ស្រុក , ក្រសួងនេះ បានបង្កើតឲ្យមានមន្ទីរព្យាបាលរោគជាច្រើន ដែលយើងធ្លាប់ហៅថា: ផ្ទះពេទ្យ ៗ នោះ ។ ផ្ទះពេទ្យដែលធំជាងគេនៅក្នុងប្រទេសខ្មែរ គឺមន្ទីរពេទ្យព្រះកេតុមាលា តាំងនៅក្រុងភ្នំពេញ ។ ក្នុងបណ្ដាមន្ទីរពេទ្យទូទៅ យើងសង្កេតឃើញ :

- មន្ទីរពេទ្យថែធ្មេញ ។
- មន្ទីរពេទ្យពិនិត្យស្ត្រីមានផ្ទៃពោះ ។
- មន្ទីរពេទ្យប្រសូតបុត្រ ។
- មន្ទីរពេទ្យកែរោគឃ្លង់ ( នៅត្រើង - កំពង់ចាម ) ។
- មន្ទីរពេទ្យកែរោគវិកលចរិត ( នៅតាខ្មៅ ) ។
- ក្រសួងអនាម័យ
- ក្រសួងពេទ្យសម្រាប់ដើរពិនិត្យជម្ងឺ (Service exterieur) ។

សព្វថ្ងៃនេះ , ក្រសួងសាធារណៈសុខាភិបាលបានខំប្រឹងប្រែងពង្រីកថែមទៀត ដើម្បីគាំទ្រសុខភាពរបស់ប្រជាពលរដ្ឋ ។ កាលបើប្រជាពលរដ្ឋប្រកបដោយសុខភាពបរិបូណ៌ហើយ ប្រជាពលរដ្ឋមានកំលាំង នឹងមានសេចក្ដីព្យាយាមក្នុងការបំពេញអាជីវកម្មរៀងៗខ្លួន ដែលនឹងនាំឲ្យប្រជាពលរដ្ឋមានកំរិតជីវភាពខ្ពង់ខ្ពស់ នឹងថ្លៃថ្នូរ ។

អស់លោករដ្ឋមន្ត្រីសាធារណៈសុខាភិបាលគឺៈ

- វេជ្ជបណ្ឌិត (Docteur)

- នាយសុខាភិបាល ( Officier de santé )
- គិលានុបដ្ឋាក (Infirmier)
- គិលានុបដ្ឋាយិកា (Infirmière)
- ឆ្មប (Sage-Femme)

មកទល់នឹងថ្ងៃដែលយើងសរសេរសៀវភៅនេះ, មន្ត្រីខ្ពស់ៗ ដែលមានសមត្ថភាពខាងវេជ្ជវិទ្យាបរិបូណ៌មាន ៖

- ១៩ វេជ្ជបណ្ឌិតចេញពីមហាវិទ្យាល័យបារាំង ។
- ៩៧ មន្ត្រីសុខាភិបាល (គ្រូពេទ្យឥណ្ឌូចិន) ។

ចំណែកគិលានុបដ្ឋាក - គិលានុបដ្ឋាយិកានឹងឆ្មប មានចំនួនច្រើន សមល្មមនឹងកិច្ចត្រូវការរបស់ប្រទេសយើង ។

ចំនួននេះមិននៅគាំងត្រឹមប៉ុណ្ណឹងទេ ចេះតែបង្កើតថែមទៅទៀត ។

ក្នុងឆ្នាំ ១៩៦០ យើងនឹងមានមន្ត្រីសុខាភិបាលថ្មី ចំនួន ១៥ រូបទៀត ។ ដល់ទៅឆ្នាំ ១៩៦១ យើងនឹងមានមន្ត្រីសុខាភិបាលថ្មីចំនួន ១៦ រូបទៀត ។

## រដ្ឋមន្ត្រីស្ថាន នៃ សាធារណៈការ

ក្រសួងសាធារណៈការ ឋិតនៅក្រោមអំណាចនៃលោក រដ្ឋមន្ត្រីសាធារណៈការ មានទីស្ដីការនៅឯក្រុងភ្នំពេញ ។ អ្នកបច្ចេកទេស (les techniciens), វិស្វករ les Ingénieurs) និងមេការទាំងឡាយ les conducteurs des travaux) ធ្វើការក្នុង ក្រសួងនេះ ។

ក្រសួងសាធារណៈការទទួលភារៈចាត់ចែងការធំ ៗ របស់ រាជការ (សាធារណៈ) មានការសង់អាគារសិក្សា, សង់មន្ទីរ ពេទ្យ, ធ្វើស្ពាន, លើកថ្នល់, ជីកព្រែក, លុបបឹងត្រពាំង ៗល ៗ ដែលជាប្រយោជន៍ដល់បណ្ដារាស្ត្រទូទៅ ។

## រដ្ឋមន្ត្រីស្ថាន ឃោសនាការជាតិ

ក្រសួងឃោសនាការជាតិ ឋិតនៅក្រោមអំណាចនៃលោក រដ្ឋមន្ត្រីឃោសនាការ ដែលមានទីស្ដីការតាំងនៅក្រុងភ្នំពេញ ។

ក្រសួងនេះមានការៈធ្វើការឃោសនាទូទៅ ប៉ុន្តែត្រូវឲ្យមានលក្ខណៈ ស្របនឹងនយោបាយរបស់រដ្ឋាភិបាល ។

– ឃោសនា ប្រាប់ប្រជារាស្ត្រឲ្យបានដឹងអំពីកិច្ចការដែលរាជរដ្ឋាភិបាលបានធ្វើ នឹងបម្រុងនឹងធ្វើ ។

– ឃោសនាប្រាប់ប្រជារាស្ត្រ អំពីអាកប្បកិរិយារបស់ប្រទេសដទៃ ចំពោះប្រទេសយើង ។

– ឃោសនាឲ្យរាស្ត្រចូលចិត្តនឹងរាជរដ្ឋាភិបាល ។

– ឃោសនាឲ្យរាស្ត្រមានសតិសម្បជញ្ញៈក្នុងអាជីវកម្ម ។

– ឃោសនាផ្តល់វប្បធម៌ជាតិដល់ប្រជារាស្ត្រ ។

– ឃោសនាឲ្យប្រជារាស្ត្រ ក្រោកប្រឆាំងគ្រប់អំពើក្បត់ ។

ហេតុនេះក្រសួងឃោសនាការ ត្រូវមានរោងពុម្ពពិសេសមួយសម្រាប់បោះពុម្ពផ្សាយ ( កាសែត , ទស្សនាវដ្តី - រូបភាព - សៀវភៅ - ខិតប័ណ្ណ - ព្រឹត្តិប័ត្រពតិមានផ្សេង ៗ ) ; មានវិទ្យភាពយន្ត , មានវិទ្យុផ្សាយសំឡេង ។ល ។

ក្រសួងឃោសនាការ ត្រួតត្រាគ្រប់សារពតិមានឯកជន

ទាំងអស់នៅក្នុងស្រុក ទឹងពិនិត្យគ្រប់សារពត៌មានបរទេសដែលនាំចូលមកលក់ក្នុងស្រុកយើង ។

## រដ្ឋមន្ត្រីស្ថាន នៃ សន្តិសុខជាតិ

ក្រសួងសន្តិសុខជាតិ ទទួលភារៈរក្សាសេចក្តីស្ងប់ស្ងៀមរៀបរយក្នុងនគរ ដើម្បីឲ្យប្រជាជនប្រកបការរកស៊ីបានដោយស្រួល ទឹងដោយយុត្តិធម៌ផង ។ ក្រសួងនេះមានរដ្ឋមន្ត្រីមួយរូបត្រួតត្រា ហើយចែកចេញជាច្រើនក្រុម ។ ក្រុមធំ ៗ មានពីរ គឺ =

១ – ក្រុមការពារលើផ្ទៃប្រទេស

២ – ក្រុមនគរបាលជាតិ

ក្រុមការពារលើផ្ទៃប្រទេស គេច្រើនហៅថា : កងរក្សាខេត្ត មានភារៈខាងការគ្រប់គ្រងសន្តិសុខក្នុងខេត្ត ក្នុងស្រុកដោយផ្ទាល់ទោសដល់ជនឃោរឃៅ ទឹងជួយសង្គ្រោះដល់ជនណាដែលមានការអាសន្នកិតភ័យ ។

ក្រុមនគរបាលជាតិ មានការៈស៊ើបសួរអង្កេតរកអ្នកណាដែលចង់បំផ្លាញប្រយោជន៍ឯកជន, ប្រយោជន៍ជាតិ ហើយទាំងមើលការខុសត្រូវក្នុងទីក្រុង ។

## រដ្ឋមន្ត្រីស្ថាន នៃ សង្គមកិច្ច

ក្រសួងសង្គមកិច្ច មានការៈជួយផ្តល់ឲ្យប្រជាជននូវគ្រឿងឧបភោគនិងគ្រឿងបរិភោគ ក្នុងពេលដែលប្រជាជនជួបប្រទះនឹងរឿងអាសន្ន ដូចជាទឹកជន់លិចផ្ទះសម្បែង, លិចស្រែក្ដី ; ភ្លើងឆេះផ្ទះ ; រន្ទះបាញ់ព្រាត់ប្រាសកូនចៅជាដើម ។

ក្រសួងសង្គមកិច្ច សង់គេហស្ថានទុកលក់ថោកឲ្យប្រជាជនក្រីក្រ ។ ជួយរកមុខរបរឲ្យមនុស្សគ្មានការធ្វើ ។ ជួយការពារកម្មករកុំឲ្យមានការរំលោភខ្លាំងពេកពីពួកនាយទុន ។ ប្រមូលមនុស្សក្រីក្រហើយពិការឲ្យទៅនៅមួយកន្លែង ដោយផ្តល់ស្បៀងអាហារឲ្យ ។ ប្រមូលក្មេងអនាថា ឲ្យទៅរៀនសូត្រមិនឲ្យដើរដេកកណ្តៀតគេឯងពាសពេញតាមទីផ្សារ ។

ក្រសួងសង្គមកិច្ចនេះ ឋិតនៅក្រោមអំណាចនៃលោករដ្ឋមន្ត្រីសង្គមកិច្ច ដែលមានទីស្តីការតាំងនៅក្រុងភ្នំពេញ ។ ក្រសួងសង្គមកិច្ចមាននៅគ្រប់ខេត្តទាំងអស់ក្នុងព្រះរាជអាណាចក្រ ។

## រដ្ឋមន្ត្រីស្ថាន នៃ ថវិកាជាតិ

ក្រសួងថវិកាជាតិ ឋិតនៅក្រោមអំណាចរបស់លោករដ្ឋមន្ត្រីថវិកាដែលមានទីស្តីការនៅក្រុងភ្នំពេញ ។ ក្រសួងថវិកាជាតិក៏ដូចជាស្ត្រីមេផ្ទះមួយរូបដែរ មានការៈរៀបចំប្រាក់ចំណូលនឹងប្រាក់ចំណាយរបស់ជាតិឲ្យបានហ្មត់ចត់ប្រាកដប្រជា ។ ស្ត្រីមេផ្ទះណាដែលគត់មត់ ( មានគំនិតមារយាទល្អ, មានការពិចារណាវែងឆ្ងាយ ) ស្ត្រីមេផ្ទះនោះ នឹងធ្វើឲ្យផ្ទះនោះ ( គ្រួសារនោះ ) មានភោគសម្បត្តិច្រើនឡើង ៗ រៀងរាល់ថ្ងៃ ៗ គឺគេមិនហ៊ានចាយវាយរហូតដល់ចំនួនប្រាក់ចំណាយច្រើនជាងចំនួនប្រាក់ចំណូល ។ ក្នុងរដ្ឋក៏ដូច្នោះដែរ, បើលោករដ្ឋមន្ត្រីថវិកា ចេះចាត់ចែងចំណូលចំណាយថវិកាឲ្យបាន

ត្រឹមត្រូវ រដ្ឋនឹងបានចំរើនកោតទ្រព្យបន្តិចម្តងដែរ ។ ក្នុងករណីណាដែលក្រសួងថវិកាចំណាយប្រាក់ចេញច្រើនជាងប្រាក់ចូល , រហូតទៅដល់មានការខ្វះខាតថែមទៀត គេហៅថាវិបត្តិថវិកា (Crise budgétaire) ។ ក្នុងខណៈនោះ លោករដ្ឋមន្ត្រីថវិកា ព្រមទាំងគណៈរដ្ឋមន្ត្រី រដ្ឋាភិបាលទាំងមូល ត្រូវទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា ( អស់លោកតំណាងរាស្ត្រ ) ។

## រដ្ឋមន្ត្រីស្ថាន នៃ ពាណិជ្ជកម្ម

ក្នុងប្រទេសសង្គមនិយម (Socialiste) កិច្ចការពាណិជ្ជកម្មក្នុងប្រទេសនិងក្រៅប្រទេស ជាការៈរបស់រាជការ ។ រាជការធ្វើជំនួញ , ដើម្បីឲ្យតម្លៃទំនិញដែលនាំចូលចុះថោកផង , ដើម្បីឲ្យទំនិញនាំចេញមានតម្លៃផង , ទឹងដើម្បីយកប្រាក់ចំណេញមកស្ថាបនាប្រទេសឲ្យបានរុងរឿង ដើម្បីជាប្រយោជន៍បណ្តារាស្ត្រទាំងអស់ក្នុងនគរ ។ ឯកជនគ្មានសិទ្ធិធ្វើជំនួញធំ ៗ យកប្រាក់ចំណេញកប់ក្តោងមកសង់គ្រឹះស្ថាន , ទិញឡាន , ឲ្យ

ហ៊ឺហាអស្ចារ្យតែម្នាក់ឯងបានទេ ។

កុងប្រទេសមូលធននិយម ( Capitaliste ) កិច្ចការពាណិជ្ជកម្ម , ឯកជនអាចធ្វើបានដោយសេរី ។ រដ្ឋាភិបាលគ្រាន់តែបង្កើតក្រសួងមួយហៅថាក្រសួងពាណិជ្ជកម្មសម្រាប់ ពិនិត្យចំនួនទំនិញដែលអាចនាំចេញទៅលក់ឯប្រទេសក្រៅបាន នឹងជួយដើររកផ្សារឲ្យឯកជននាំទំនិញនោះៗ ទៅលក់ ។ ការនាំចូលក៏ជាភារៈរបស់ក្រសួងនេះត្រួតពិនិត្យដែរ ។ ហេតុនេះក្រសួងពាណិជ្ជកម្មមានមន្ទីរចាត់ការពីរផ្នែក គឺៈមន្ទីរចាត់ការពាណិជ្ជកម្មកុងប្រទេស នឹងមន្ទីរចាត់ការពាណិជ្ជកម្មក្រៅប្រទេស ។

នាយទុនណា ( ថៅកែណា ) ដែលចង់ដឹកនាំអង្ករពីប្រទេសខ្មែរ ទៅលក់ឯបរទេស ត្រូវទៅទាក់ទងនឹងក្រសួងពាណិជ្ជកម្មក្រៅប្រទេស; ក្រសួងនេះជួយរកផ្សារឲ្យនាំចេញទៅលក់ ដូចជាហុង - កុង - តូក្យូ ឬ ទៅម៉ាឡាយូជាដើម ។

ក្រសួងពាណិជ្ជកម្មខ្មែរយើងឋិតនៅក្រោមអំណាចនៃលោករដ្ឋមន្ត្រីមួយរូប ដែលមានទីស្តីការតាំងនៅក្រុងភ្នំពេញ ។

## រដ្ឋមន្ត្រីស្ថាននៃកសិកម្ម

កសិកម្ម គឺការដាំដំណាំដូចជាដាំស្រូវ - ពោត - សណ្ដែក ល្ង - កប្បាស - ។ល។ ដែលបារាំងសែសថា « Agriculture » ប្រទេសខ្មែរយើងជាប្រទេសកសិកម្ម មិនមែនជាប្រទេសឧស្សាហកម្ម ដូចសហភាពសូវៀត-អាមេរិក-បារាំងទេ ។ ដូច្នេះការបង្កើតឲ្យមានក្រសួងកសិកម្ម ជាការចាំបាច់បំផុតសម្រាប់ប្រទេសយើង។ ក្រសួងនេះត្រូវស្ថិតនៅក្រោមការត្រួតត្រានៃរដ្ឋមន្ត្រីមួយរូប ហើយដែលមានអ្នកបច្ចេកទេស , វិស្វករកសិកម្មជាច្រើននៅធ្វើការក្នុងទីនោះ ។

ភារៈរបស់ក្រសួងនេះគឺ ៖

១– ស្រាវជ្រាវទីដាំដុះដំណាំពិសោធដោយខ្លួនឯង ។

២– អប់រំប្រជាជនក្នុងការដាំដុះដំណាំផ្សេង ៗ ដែលរើសនាទីដីដោយឡែក ៗ អំពីគ្នា ។

— ការរើសដី

—

- ការរើសពូជ
- ការបណ្ដុះពូជ
- ការសាបព្រោះ
- ការដាំ
- ការដាក់ជី
- ប្រភេទទាំងឡាយនៃដី
- ការថែរក្សា
- ការផលិតដំណាំ
- ការថែរក្សាផលិតផលតាមរបៀបវិទ្យាសាស្ត្រ ។

ហេតុនេះក្រសួងកសិកម្មត្រូវមានអ្នក បច្ចេកទេសជាច្រើន, ព្រោះក្រសួងនេះទុកដូចជាគ្រូបង្ហាត់របស់បងប្អូនកសិករទាំងឡាយក្នុងការប្រកបអាជីវកម្មរៀង ៗ ខ្លួន ។

ក្រសួងកសិកម្ម ត្រូវមានសាលាសម្រាប់ហ្វឹកហ្វឺនបុគ្គលិករបស់ខ្លួន, ត្រូវមានដីច្រើនសម្រាប់ដាំដំណាំពិសោធ នឹងធ្វើជាគំរូ ; ត្រូវមានការសែត, ទស្សនាវដ្ដីរូបភាពខាងកសិកម្ម

ត្រូវតាំងមានខ្សែភាពយន្ត សម្រាប់បញ្ចាំងឲ្យប្រជាជនមើលឃើញវិធីថ្មីៗ ទាំងឡាយ ដែលគេអនុវត្តបានផលល្អក្នុងតំបន់កសិកម្មក្នុងពិភពលោក ។

ទីស្តីការក្រសួងកសិកម្មខ្មែរយើង តាំងនៅក្រុងភ្នំពេញ ។

## រដ្ឋមន្ត្រីស្ថានផែនការជាតិ

ប្រទេសនិមួយៗត្រូវការស្ថាបនាឲ្យបានរុងរឿងនិងសម្បូណ៌សប្បាយជាចាំបាច់ ។ ការស្ថាបនាផ្ទះមួយ, គេត្រូវមានផែនផ្ទះនិងសម្ភារៈជាដំបូង ; ក្រោយមកត្រូវមានប្រាក់សម្រាប់សង់ និងរកជាងចំណានៗ មកសង់ឲ្យបានល្អ ។ ដើម្បីស្ថាបនាប្រទេសគេត្រូវមានផែនការដែរ ។ រដ្ឋាភិបាល ឬ ចលនាគណៈបក្សនយោបាយដែលបានឈ្នះឆ្នោតចូលមកកាន់កាប់ការរដ្ឋ ជាអ្នកមេគំនិតនៃផែនការ ។ ដូចជាផែនការ ២ ឆ្នាំ, ផែនការ ៥ ឆ្នាំរបស់ចលនាសង្គមរាស្ត្រនិយមនៅប្រទេសយើង, ផែនការ ៧ ឆ្នាំរបស់បក្សកុម្មុយនិស្តនៅសហភាពសូវៀត ។ល។ . . . ក្រសួង

ផែនការ ជាអ្នកកាន់ផែនការរបស់រដ្ឋាភិបាលដោយផ្ទាល់ ។ ហេតុនេះរដ្ឋមន្ត្រីក្រសួងផែនការ ត្រូវមានសមត្ថភាពគ្រប់គ្រាន់ និងមានស្មារតីកសាងជាតិមាតុប្រទេសយ៉ាងបរិបូណ៌ ។

ទីស្តីការរដ្ឋមន្ត្រីក្រសួងផែនការខ្មែរយើង តាំងនៅក្រុងភ្នំពេញ ។ សព្វថ្ងៃនេះ (ក្នុងពេលសរសេរសៀវភៅហ្នឹង ១៩៦០ ) ឯកឧត្តមញឹក-ជូ-ឡុង ជារដ្ឋមន្ត្រីនៃផែនការជាតិ ។

## រដ្ឋមន្ត្រីស្ថាននៃយុត្តិធម៌

ខេមរយុត្តិធម្មាធិការ ស្ថិតក្រោមអំណាចលោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលមានទីស្តីការនៅក្រុងភ្នំពេញ។ការៈរបស់ក្រសួងនេះគឺចាត់ចែងខាងកិច្ចការអភិបាល ('ffaires administratives) ក្នុងខេមរៈយុត្តិធម្មាធិការ ។ ក្រសួងនេះគ្មានអំណាចបញ្ជាឲ្យចៅក្រមកាត់ទោសប៉ុណ្ណេះឬប៉ុណ្ណោះដល់ជនទុច្ចរិតឯណាមួយទេ ។ ការជំនុំជំរះក្តីស្រេចនៅលើអំណាចតុលាការ ។ ប៉ុន្តែចៅក្រមតាំង

ឡាយ, កាលបើងឿងឆ្ងល់ ឬ មិនច្បាស់លាស់នឹងច្បាប់អ្វីមួយ អាចឡើងទៅសួរឯក្រសួងយុត្តិធម៌បាន ព្រោះនៅក្នុងក្រសួងនេះមានអ្នកចេះច្បាប់យ៉ាងចំណាន ៗ ជាច្រើន ៗ

---

# អំពីអង្គការតុលាការ

ប្រទេសកម្ពុជាយើង កាន់លទ្ធិប្រជាធិបតេយ្យ ស្រឹយដ្ឋសភា ដូចជាប្រទេសថៃ-លាវ-ចិនមហាប្រទេសអង់គ្លេសនៅទ្វីបអឺរ៉ុប ដែរ ។ រដ្ឋធម្មនុញ្ញយើងដែលមានលក្ខណៈប្រជាធិបតេយ្យសុទ្ធសាធ បានចែងច្បាស់ថា: រដ្ឋយើង (កម្ពុជា) មានអង្គការបីដាច់ដោយឡែកអំពីគ្នា គឺ :

១ = អង្គការនីតិបញ្ញត្តិ (រដ្ឋសភា)

២ = អង្គការនីតិប្រតិបត្តិ (រដ្ឋាភិបាល)

៣ = អង្គការតុលាការ (ក្រសួងយុត្តិធម្មាធិការ)

## អង្គការតុលាការនេះជាអ្វី?

អង្គការនេះជាអង្គការពិសេសមួយ មានលក្ខណៈឯករាជ្យបរិបូណ៌ ហើយមានភារៈស្វែងរកសេចក្តីយុត្តិធម៌មហាប្រសើរ ជូនប្រជារាស្ត្រទូទៅក្នុងព្រះរាជអាណាចក្រ ។ អង្គការនេះមានលោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជានាយក ; ប៉ុន្តែមុខងាររបស់លោក

រដ្ឋមន្ត្រី គឺគ្រាន់តែត្រួតត្រាការខុសត្រូវខាងកិច្ចការរដ្ឋបាល និងខាងផ្នែកនយោបាយតែប៉ុណ្ណោះ, រីឯខាងកិច្ចការបច្ចេកទេស គឺការអនុវត្តន៍ច្បាប់ទូទៅមានអស់លោកចៅក្រមជាអ្នកទទួលភារៈ។ ហេតុនេះហើយបានជាគេថា: ចៅក្រមជាអ្នកកាន់អំណាចតុលាការ ។ អំណាចតុលាការ គឺអំណាចកាត់សេចក្ដី-រកខុសរកត្រូវតាមដោយគតិយុត្តិធម៌ ។ ច្បាប់តុលាការមានត្រាទុកក្នុងច្បាប់ព្រហ្មទណ្ឌ និងក្នុងច្បាប់រដ្ឋប្បវេណី ។ នៅពេលកាត់ក្ដីម្ដងៗ អស់លោកចៅក្រម ត្រូវអនុវត្តច្បាប់នេះយ៉ាងហ្មត់ចត់បំផុត ។

ដើម្បីគាំទ្រ និងការពារសេចក្ដីយុត្តិធម៌កុំឲ្យមានល្អៀង គេបានបង្កើតក្រុមមួយផ្សេងទៀតហៅថា: **ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ។** ក្រុមប្រឹក្សាជាន់ខ្ពស់នេះមានលោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអធិបតី; មានសមាជិក ២ រូបតាក់តែងដោយព្រះមហាក្សត្រ, ហើយនិងសមាជិក ២រូប

ទៀត ជ្រើសតាំងដោយរដ្ឋសភា ។

ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការមានការៈមើលត្រួតត្រា ការអនុវត្តន៍ច្បាប់របស់ពួកចៅក្រមទាំងឡាយឲ្យបានត្រឹមត្រូវ ។

## ព្រះមហាក្សត្រនិងអង្គការតុលាការ

ក្នុងអំណាចតុលាការ, ព្រះមហាក្សត្រដ៏ជាទីគោរពរបស់ប្រជារាស្ត្រ ទ្រង់មានរាជសិទ្ធិ អាចដោះលែងមនុស្សទោស ឬបន្ថយទោសដល់អ្នកដែលជាប់ទោសបានដែរ ។

ឧបមាបីដូចជាឈ្មោះ « ក » ត្រូវជាប់ចោទអំពីបទអ្វីមួយ ហើយតុលាការមិនទាន់ជំនុំជំរះទេ គេគ្រាន់តែយកទៅផ្ញើទុកក្នុងគុកសិន ( Mandat de dépôt ) ហើយបើអ្នកជាប់ឃុំ, នោះបានធ្វើបុតហ្វាយសុំទោសព្រះមហាក្សត្រនោះ ព្រះមហាក្សត្រទ្រង់អាចនឹងដោះលែងបាន តាមព្រះរាជយោបល់របស់ព្រះអង្គ ។ មួយវិញទៀត បើពួកចៅក្រមបានកាត់ទោសឈ្មោះ « ខ » ប៉ុណ្ណេះប៉ុណ្ណោះឆ្នាំ ក៏ព្រះមហាក្សត្រទ្រង់អាចបន្ថយទោសនោះ

ឲ្យនៅតែត្រឹមណោះ ឬ ត្រឹមណោះឆ្នាំបានដែរ ៗ ជាពិសេសនៅឱកាសបុណ្យចំរើនព្រះជន្មវស្សាវៀងពល់ឆ្នាំ (បុណ្យតាំងតុ) ព្រះមហាក្សត្រទ្រង់ព្រះមេត្តាប្រោស ប្រណីបន្ថយទោសឲ្យអ្នកទោសគ្រប់ ៗ គ្នា ៗ នេះគឺអាស្រ័យទសពិធរាជធម៌របស់ព្រះមហាក្សត្រនៃប្រទេសខ្មែរយើងដែរ ៗ ប្រទេសដទៃខ្លះ ពុំមានរបស់នាល្អដូច្នេះទេ ៗ

## អំពីគុណាគារជាន់ខ្ពស់

គុណាគារជាន់ខ្ពស់ គឺជាក្រុមពិសេសមួយក្នុងអង្គការគុណាគារដែរ ៗ សាលាដំរុំជំរះក្ដីតាំងពីបុរាណកន្លងព្រះរាជអាណាចក្រ មិនអាចយកខ្លួនរដ្ឋមន្ត្រីឯណាមួយទៅកាត់ក្ដីបានទេ ៗ ហេតុនេះហើយ បើមានរដ្ឋមន្ត្រីឯណាមួយបានប្រព្រឹត្តខុសនឹងច្បាប់,រដ្ឋសភាត្រូវយកសំណុំរឿងនោះទៅបញ្ជូនដល់គុណាគារជាន់ខ្ពស់ ៗ គុណាគារជាន់ខ្ពស់ គឺជាក្រុមមួយដែលគេបាត់តាំងឡើងនៅពេលដែលគេត្រូវការឲ្យមាន ៗ គុណាគារជាន់

ខ្ពស់នេះមានសមាជិក ៥ រូប គឺ គេជ្រើសរើសយកចៅក្រមជាន់ខ្ពស់ ២ រូប, យកអ្នកតំណាងក្រសួង ១ រូប, ហើយនឹងយកសមាជិកនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ ២ រូបទៀត ។

## អំពីចាងហ្វាងសាលា
## ព្រះរាជអាជ្ញា – សុភាចារបុរស – មេធាវី

ចៅក្រមដែលចេញជំនុំជំរះកាត់ក្ដី, សម្រេចថា: កូនក្ដីណាខុស, កូនក្ដីណាត្រូវ, ដាក់ទោសប៉ុណ្ណេះ ឬ ប៉ុណ្ណោះឆ្នាំ តាមច្បាប់តុលាការ គេហៅថា: ចាងហ្វាងសាលា ។

ចៅក្រមដែលចាំផ្សំសំណុំរឿងទោទ ហៅថាព្រះរាជអាជ្ញា គឺជាអ្នកដំណាងព្រះមហាក្សត្រ ដើម្បីការពារប្រយោជន៍សង្គម ប្រឆាំងទល់នឹងប្រយោជន៍ស្វនត្វរបស់បុគ្គលម្នាក់ៗ ។ នៅពេលកាត់ក្ដីម្ដងៗ មុននឹងសម្រេចសេចក្ដី, លោកចាងហ្វាងសាលាតែងតែសួរយោបល់លោកព្រះរាជអាជ្ញាជាដរាប ។ ជួនកាលព្រះរាជអាជ្ញា សុំឲ្យចាងហ្វាងសាលាបន្ថយទោស ជួនកាលសុំបន្ថែម

ព្រលឹងខ្មែរ

ទោសឲ្យធ្ងន់ថែមទៀតក៏មានដែរ ។ ព្រះរាជអាជ្ញានេះហើយ ដែលជាអ្នកចុះហត្ថលេខាលើដីកាឲ្យនាំខ្លួន ឬដីកាឲ្យឃុំខ្លួន ។

ចំណែកឯទៅក្រុមមួយទៀត មានករណីយកិច្ចស៊ើបសួរ អង្កេតអ្នកដើមចោទ, អ្នកចុងចោទ, ឬអ្នកជាប់ចោទមុន ដែលនឹងប្រគល់សំណុំរឿង ទៅឲ្យតាន់ហ្វាន់សាលាជំនុំជំរះកាត់ក្ដីនោះគេហៅថា: សុភាចារបុរស ។

នៅពេលដែលលោកតាន់ហ្វាន់សាលាជំនុំជំរះកាត់ក្ដី គេឃើញមានបុគ្គលម្នាក់ ឬពីរនាក់ ឬច្រើននាក់ទៀត ជាអ្នកកាន់ជើងក្ដី ជួយការពារក្ដី, ជួយសុំតាន់ហ្វាន់សាលាឲ្យបន្ធូរទោសឲ្យក្ដី ។ បុគ្គលនេះ គេហៅថា: មេធាវី ។ មេធាវីមិនមែនជាសមាជិកកង់អង្គការតុលាការទេ គឺជាអ្នកប្រកបវិជ្ជាជីវៈសេរី ។ គេបញ្ចេញមុខកាន់ជើងក្ដី លុះត្រាតែក្ដីនោះបានជូនផលប្រយោជន៍ទៅគេដែរ ។ បើពោលពីសមត្ថភាពវិញ គឺគេមានគ្រប់គ្រាន់ ព្រោះគេបញ្ចេញមុខធ្វើមេធាវីនេះ ដោយបានសេចក្ដីអនុញ្ញាតិត្រឹមត្រូវតាមច្បាប់ ។

# អំពីសាលាលហុ

សាលាលហុសម្រាប់ជំនុំជំរះបទលហុ ( ស្រាលបំផុត ) គឺទោសល្មើសផ្ទុសប្រហែសនឹងច្បាប់បញ្ញត្តិ ដូចជាទោសដែលមិនបានចុះសំបុត្រកំណើតឲ្យកូនប្រុស-ស្រី, ទោសដែលមិនបានធ្វើអត្តសញ្ញាណប័ណ្ណ, ទោសដែលធ្វើបុណ្យទានអ្វីមួយមិនបានសុំច្បាប់ ។ល។ នឹង ។ល។...

សាលាលហុ មានអំណាចកាត់សេចក្ដីធ្វើទោសដូចខាងក្រោមនេះ ៖

១ — បើដាក់គុក-អាចដាក់បានពី ១ ថ្ងៃទៅ ៥ ថ្ងៃ យ៉ាងច្រើនបំផុត ( មានទុកផ្លូវឧទ្ធរណ៍ ) ។

២ — បើពិន័យជាប្រាក់-អាចពិន័យបានពីត្រឹម១៥ រៀល ទៅដល់ ១៥០ រៀល (ឥតទុកផ្លូវឧទ្ធរណ៍ទេ ប៉ុន្តែអាចប្ដឹងឡើងទៅសាលាវិនិច្ឆ័យបានដែរ ) ។

សាលាលហុមានតាំងហ្នឹងតែមួយទេ ដែលមានមុខការជំនុំជំរះនឹងសម្រេចកិច្ចទាំងឡាយជាផ្លូវការ ។ មានក្រឡាបញ្ជីម្នាក់

ជួយធ្វើកិច្ចការផ្សេង ៗ ព្រមទាំងអមតាន់ហ្វាងសាលាក្នុងពេល ជំនុំជំរះម្តង ៗ ។

ក្នុងប្រទេសខ្មែរយើង មានសាលាលហុតែពីរទេ គឺមាន នៅក្រុងភ្នំពេញមួយ ដែលយើងធ្លាប់ហៅថាសាលាលុឃុន ( តាមភាសាសៀម ) យើងមាននៅក្នុងខេត្តបាត់ដំបងមួយទៀត។ ចំណែកឯខេត្តនានាវិញយើងធ្វើសាលាលហុ ( ឬលុឃុន ) នឹង សាលាដំបូង ៗ លោកតាន់ហ្វាងសាលាដំបូង ក៏មានមុខងារ ជាតាន់ហ្វាងសាលាលហុដែរ ។ នៅប្រទេសជិតខាងយើង ដូចជាវៀតណាមខាងត្បូង ( កម្ពុជាក្រោម ) មន្ត្រីឃុំម្នាក់ បំពេញមុខងារជាតាន់ហ្វាងសាលាលហុផង ជាស្មៀនការនគរបាល ក្នុងឃុំផង ដែលគេឲ្យឈ្មោះថា « ហឿងក្វាន់ » ។

## អំពីសាលាដំបូង

សាលាដំបូង មានតាំងនៅគ្រប់ខេត្តទាំងអស់ក្នុងព្រះរាជាណាចក្រ ។ នៅសាលាដំបូងនីមួយ ៗ មានតាន់ហ្វាងសាលា ,

មានព្រះរាជអាជ្ញា ( អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ), មាន សុភាចារបុរស ( តិចឬច្រើនតាមខេត្ត - ភ្នំពេញមាន ៦ នាក់ ), មានក្រឡាបញ្ជី, សមុហបញ្ជី និងពួកស្មៀន ។

សាលាដំបូង សម្រាប់ជំនុំជំរះកាត់សេចក្ដីរឿងអាជ្ញាគតិ បានត្រឹមតែបទមជ្ឈិមទេ គឺ ៖

១ – បើដាក់គុក - ដាក់បានពី ៦ ថ្ងៃទៅ ៥ ឆ្នាំ យ៉ាងច្រើន ( ទុកផ្លូវឧទ្ធរណ៍ )

២ – បើពិន័យជាប្រាក់ - ពិន័យបានពីត្រឹម ១៥១ រៀល ទៅដល់ ៥០.០០០ រៀល ( ទុកផ្លូវឧទ្ធរណ៍ដែរ ) ។

ទោសមជ្ឈិមនេះ ច្បាប់បានចែកចេញជាពីថ្នាក់ ដូចត ទៅនេះ ៖

ក– បទមជ្ឈិមថ្នាក់ទី១
- ដាក់គុកពី ៦ ថ្ងៃទៅ ៣០ ថ្ងៃ (១ខែ)
  ឬ ក៏
- ពិន័យពី១៥១រៀលទៅ១.២០០រៀល។

ខ – បទមជ្ឈិមថ្នាក់ទី២

- – ដាក់គុកពី៣០ថ្ងៃទៅដល់១ឆ្នាំ
- ឬ ក៏
- – ពិន័យពី ១.២០១៛ ទៅ ៤.០០០៛ ។

គ – បទមជ្ឈិមថ្នាក់ទី៣

- – ដាក់គុកពី ១ឆ្នាំទៅដល់ ៥ឆ្នាំ
- ឬ ក៏
- – ពិន័យពី៤.០០១៛ ទៅ៤០.០០០៛ ។

ចំណាំ – ទោសមជ្ឈិមទាំង៣ ថ្នាក់នេះ ជួនកាលគេដាក់គុកផង ពិន័យផង, ជួនកាលគ្រាន់តែពិន័យ; ជួនកាលទៀត គ្រាន់តែដាក់គុក (ស្រេចនៅលើតាងហ្វាន់សាលា) ។

## អំពីសាលាក្រុមហោទ

សាលាក្រុមហោទ តាំងនៅក្រុងភ្នំពេញ សម្រាប់ពិនិត្យមើលពាក្យហោទផ្សេង ៗ ដែលគូក្តីមិនសុខចិត្តនឹងការជំនុំជំរះ នៅសាលាដំបូងនានា ៗ លុះបានពិចារណាមើលរឿងទាំងនោះឃើញ ថាបានត្រឹមត្រូវដូចកូនក្តីមិនសុខចិត្តមែន ដោយមានបន្ទោះកិច្ច

ម្យ៉ាងៗ ពុំបានពោលសេចក្ដីបរិបូណ៌ , សាលាក្រុមទោទក៏ធ្វើពតិ-មាន តាមហេតុដែលខ្លួនពិនិត្យឃើញបញ្ជូនទៅឲ្យសាលាឧទ្ធរណ៍ជំនុំជំរះ ។

សាលាក្រុមទោទ ជាសាលាជំនួយនៃសាលាឧទ្ធរណ៍ ។ សាលានេះឥតមានភារៈជំរះកាត់ទោសក្ដីទេ ។ សាលាហ្នឹងគ្រាន់តែជាក្នុកជាប្រមុះរបស់សាលាឧទ្ធរណ៍តែប៉ុណ្ណោះឯង ។

## អំពីសាលាឧទ្ធរណ៍

កូនក្ដីណាដែលមិនសុខចិត្តនឹងការជំនុំជំរៈ របស់លោកចាងហ្វាងសាលាលហុ ឬ សាលាដំបូងនានាក្នុងព្រះរាជអាណាចក្រ , កូនក្ដីនោះអាចធ្វើពាក្យឡើងទៅសាលាឧទ្ធរណ៍ឲ្យគេកាត់ក្ដីឲ្យខ្លួនម្ដងទៀត ។ ក៏ប៉ុន្តែ , បើលោកចាងហ្វាងសាលាលហុ ឬ សាលាដំបូងបានសម្រេចសេចក្ដីពិន័យ ឬ ធ្វើទោសដាក់គុកកូនក្ដី ដោយឥតមានបើកផ្លូវឧទ្ធរណ៍ឲ្យទេ , នោះកូនក្ដីនោះពុំមានសិទ្ធិឡើងទៅតរ៉ាទៅសាលាឧទ្ធរណ៍ទៀតឡើយ ។ ប្រទេសខ្មែរយើង, សាលា

ខ្ទរណ៍មានតែមួយទេ, តាំងទៅក្នុងកដជាទីក្រុងពេញ ៗ នៅក្នុងសាលាខ្ទរណ៍ មានលោកចាងហ្វាងសាលាខ្ទរណ៍ជាធាយក, មានលោកអគ្គព្រះរាជអាជ្ញា, មានលោកព្រះរាជអាជ្ញារង, អស់លោកក្រឡាបញ្ជី, សមុហាបញ្ជីនិងពួកស្មៀនជាច្រើនទៀត ៗ

កូនក្តីណាដែលឡើងមកដល់សាលាខ្ទរណ៍ហើយ ៗ នៅតែមិនសុខចិត្តនឹងកិច្ចជំនុំជំរះរបស់សាលាខ្ទរណ៍-ទៀត, នោះកូនក្តីនោះអាចធ្វើពាក្យឡើងទៅសាលាវិនិច្ឆ័យបានទៀត ៗ តាមធម្មតា, នៅសាលាខ្ទរណ៍ គេច្រើនតែបន្ថយទោសខ្លះឱ្យកូនក្តី ឬក៏តេជ៍កល់សាលក្រមរបស់សាលាតំរោម ( សាលាលហុ ឬ សាលាដំបូង ) ទុកជាបានការ ៗ យើងពុំសូវឃើញមានការបន្ថែមទោសទៅលើកូនក្តីទេ ៗ ហេតុនេះកូនក្តីដែលឡើងមកតវ៉ាដល់សាលាខ្ទរណ៍ហើយ ច្រើនតែបញ្ចប់ការទាមទារតវ៉ារបស់ខ្លួននៅត្រឹមសាលក្រមរបស់សាលាខ្ទរណ៍នេះឯង ៗ

## អំពីសាលាឧក្រិដ្ឋ

សាលាឧក្រិដ្ឋ សម្រាប់ជំនុំជំរះទោសធ្ងន់ដែលចូលជាបទឧក្រិដ្ឋ ដូចជាទោសលួចដុតផ្ទះគេ, លួចសម្លាប់គេ, លួចចាប់កូនក្រមុំឬប្រពន្ធរបស់គេ ឬក៏បំបាត់ថវិកាជាតិជាដើម ។ល។ សាលាឧក្រិដ្ឋនៅស្រុកខ្មែរមានតែមួយទេ បានតាំងនៅក្នុងរាជធានីភ្នំពេញ ។ បទឧក្រិដ្ឋផ្សេងៗ ដែលបានកើតឡើងក្នុងខេត្តនានា ត្រូវនាំយកទៅជំនុំជំរះនៅឯក្រុងភ្នំពេញទាំងអស់ ។

បទឧក្រិដ្ឋនេះ ច្បាប់បានចែកជាបីសណ្ឋានដូចតទៅៈ

១ - បទឧក្រិដ្ឋថ្នាក់ទី ១ - ត្រូវដាក់គុកហើយបង្ខំឲ្យធ្វើការជាទម្ងន់ ចំនួនប៉ុណ្ណោះឬប៉ុណ្ណោះឆ្នាំ គិតតាំងពី ៥ ឆ្នាំឡើងទៅ ។

២ - បទឧក្រិដ្ឋថ្នាក់ទី ២ - ត្រូវដាក់គុកហើយបង្ខំឲ្យធ្វើការជាទម្ងន់ អស់ ១ ជីវិត (កាលជំនាន់អាណានិគម បាកាំងមានកាត់ទោសដល់ទៅ ២ ឬ ៣

ជីវិតផង ) ។

៣ - បទឧក្រិដ្ឋថ្នាក់ទី៣ - ត្រូវប្រហារជីវិតចោល (ដោយម៉ាស៊ីនកាត់ក ឬ ដោយនាំយកទៅបាញ់ចោល ) ។

បើកូនក្តីណាមិនសុខចិត្តនឹងសាលក្រម សាលាឧក្រិដ្ឋទេ, នោះកូនក្តីនោះអាចធ្វើពាក្យឡើងទៅសាលាវិនិច្ឆ័យបានទៀត ។

នៅក្នុងសាលាឧក្រិដ្ឋមានលោកចាងហ្វាងសាលា, លោកអគ្គព្រះរាជអាជ្ញា, លោកព្រះរាជអាជ្ញារង លោកសុភាចារបុរស, អស់លោកក្រឡាបញ្ជី, សមុហបញ្ជី និងពួកស្មៀនជាច្រើន ។

## អំពីសាលាវិនិច្ឆ័យ

សាលាវិនិច្ឆ័យមានតែមួយ តាំងនៅក្រុងភ្នំពេញ ។ គឺជាសាលាធំបំផុតសម្រាប់ពិនិត្យរឿងហេតុ និងជំនុំជំរះសាឡើងវិញនូវរឿងណាដែលគូវិវាទប្តឹងសាទុក្ខ មិនសុខចិត្តនឹងសាលក្រមរបស់សាលាលហុ - សាលាដំបូង - សាលាឧទ្ធរណ៍ និងសាលា

ឧក្រិដ្ឋ ។ បើពិភាក្សាទៅឃើញថា សាលក្រមរបស់សាលាជាន់ក្រោម មិនបានត្រឹមត្រូវតាមច្បាប់ ក៏ជំនុំជំរះសាថ្មីម្ដងទៀតឲ្យបានសុចរិត-យុត្តិធម៌ឡើង ; បើឃើញថា : សាលក្រមនៅសាលាជាន់ក្រោមទាំងឡាយបានត្រឹមត្រូវតាមច្បាប់ហើយ ក៏បដិ-សេធពាក្យបណ្ដឹងសាទុក្ខរបស់គូវិវាទចេញ គឺដំកល់សាលក្រមចាស់ទុកជាបានការ ។

សាលាជំនុំជំរះក្ដីនៅប្រទេសខ្មែរផុតអស់ត្រឹមសាលាវិនិច្ឆ័យនេះហើយ ។

## អំពីតំណែងសក្ដិមន្ត្រីតុលាការ<br>នៅប្រទេសខ្មែរ

១- រាជធានីភ្នំពេញ

ចាងហ្វាងសាលាវិច្ឆ័យ= ឧកញ៉ាមហាឥស្សរាធិបតី ។

ចាងហ្វាងសាលាឧក្រិដ្ឋ= ឧកញ៉ាឥស្សរៈវិនិច្ឆ័យ ។

តាងហ្វាងសាលាឧទ្ធរណ៍= ឧកញ៉ាមហាវិនិច្ឆ័យ ១

តាងហ្វាងសាលាលហុន= ឧកញ៉ាពិភក្តិវិនិច្ឆ័យ ១

២ - ខេត្តកំពង់ចាម.

តាងហ្វាងសាលាដំបូង= ឧកញ៉ាពិជ័យវិនិច្ឆ័យ ១

៣ - ខេត្តកំពត.

តាងហ្វាងសាលាដំបូង= ឧកញ៉ាទេសាវិនិច្ឆ័យ ១

៤ - ខេត្តតាកែវ.

តាងហ្វាងសាលាដំបូង= ឧកញ៉ាតេជះវិនិច្ឆ័យ ១

៥ - ខេត្តព្រៃវែង.

តាងហ្វាងសាលាដំបូង= ឧកញ៉ានរះវិនិច្ឆ័យ ១

៦ - ខេត្តស្វាយរៀង.

តាងហ្វាងសាលាដំបូង= ឧកញ៉ាសូរវិនិច្ឆ័យ ១

៧ - ខេត្តកំពង់ធំ.

តាងហ្វាងសាលាដំបូង= ឧកញ៉ាមហៃវិនិច្ឆ័យ ១

៨ - ខេត្តសៀមរាប.

ចៅហ្វាយសាលាដំបូង= ឧកញ៉ាសំរេចវិនិច្ឆ័យ ។

៩ - ខេត្តពោធិសាត់.

ចៅហ្វាយសាលាដំបូង= ឧកញ៉ាសុភាវិនិច្ឆ័យ ។

១០ - ខេត្តកំពង់ឆ្នាំង.

ចៅហ្វាយសាលាដំបូង= ឧកញ៉ាឥទ្ធិវិនិច្ឆ័យ ។

១១ - ខេត្តកំពង់ស្ពឺ.

ចៅហ្វាយសាលាដំបូង= ឧកញ៉ាសិទ្ធិវិនិច្ឆ័យ ។

១២ - ខេត្តក្រចេះ.

ចៅហ្វាយសាលាដំបូង= ឧកញ៉ាចេស្តាវិនិច្ឆ័យ ។

១៣ - ខេត្តស្ទឹងត្រែង.

ចៅហ្វាយសាលាដំបូង= ឧកញ៉ានទីវិនិច្ឆ័យ ។

១៤ - ខេត្តបាត់ដំបង.

ចៅហ្វាយសាលាដំបូង = ឧកញ៉ាឧត្តមកាសិត ។

១៥ - ខេត្តកោះកុង.

(មិនទាន់បានឯកសារ)

១៦ - ខេត្តរតនៈគិរី .

( មិនទាន់បានឯកសារ )

# ព្រះរាជអាណាចក្រកម្ពុជា

ប្រទេសខ្មែរយើងឈ្មោះ «កម្ពុជា» ។ កម្ពុជាជារដ្ឋរាជានិយម កាន់លទ្ធិប្រជាធិបតេយ្យ មានរដ្ឋធម្មនុញ្ញតាំងពីឆ្នាំ ១៩៤៧ មក ។ កម្ពុជាបានរើបំរះចេញផុតពីនឹមអាណានិគមបារាំង កាលពីឆ្នាំ ១៩៥៣ ដោយការដឹកនាំដ៏ឈ្លាសវៃ នៃសម្ដេចព្រះ នរោត្តម - សីហនុ ។ កម្ពុជាជារដ្ឋឯករាជ្យបរិបូណ៌ បានចូលជាសមាជិកនៃអង្គការសហប្រជាជាតិ កាលពីថ្ងៃទី ១៤ ធ្នូ ឆ្នាំ ១.៩៥៥ ។ សព្វថ្ងៃនេះ កម្ពុជាប្រកាន់នយោបាយអព្យាក្រឹតនិងសន្តិភាព ។

របៀបចាត់ចែងកិច្ចការរដ្ឋ, កម្ពុជាមានគ្រប់អង្គការដូចមហាប្រទេសឯករាជ្យនានាដែរ គឺមានអង្គការនីតិបញ្ញត្តិ (រដ្ឋសភា) អង្គការនីតិប្រតិបត្តិ (រាជរដ្ឋាភិបាល) និងអង្គការតុលាការ (ខេមរៈយុត្តិធម្មាធិការ) ។ ក្រៅពីនេះ កម្ពុជាមានអង្គការសារពត៌មានជាច្រើនទៀត ដែលជាកំឡាំងទី ៤ របស់រដ្ឋ ។

# អំពីព្រះមហាក្សត្រ

ព្រះមហាក្សត្រទ្រង់ជាអគ្គប្រមុខនៃរដ្ឋ, ជាទីគោរពសក្ការៈ, នរណានឹងល្មើសពុំបាន ។ និតិភាពនៃព្រះមហាក្សត្រ ត្រូវកំណត់តាំងពីព្រះជន្មាយុ ១៨ ព្រះវស្សា ។

ព្រះមហាក្សត្រទ្រង់នូវរាជសិទ្ធិរំលាយរដ្ឋសភា (តំណាងរាស្ត្រ) បាន ។ ទ្រង់ជ្រើសយកនាយករដ្ឋមន្ត្រី (ប្រមុខរដ្ឋាភិបាល) ។ ទ្រង់ជាអធិបតីទីប្រជុំគណៈរដ្ឋមន្ត្រី ។ ទ្រង់បង្កើតព្រមទាំងព្រះរាជទានឋានន្តរសក្តិខាងស៊ីវិលនិងខាងទាហាន ។ ទ្រង់នូវរាជសិទ្ធិលើកលែងទោស ។ ទ្រង់ជាអគ្គប្រមុខលើកម្លាំងទាហានទាំងឡាយ ។

ព្រះមហាក្សត្របច្ចុប្បន្ននេះ ទ្រង់ព្រះនាមព្រះសុរាម្រឹត ហើយនិងព្រះមហាក្សត្រិយានី ព្រះនាមព្រះកុសុមនារីរ័ត្ន ។ អគ្គប្រមុខរដ្ឋទ្រង់គង់នៅក្នុងព្រះបរមរាជវាំងនាក្រុងចតុមុខ - ភ្នំពេញ ។

# ការបែងចែកអាណាខេត្ត

ប្រទេសកម្ពុជាចែកចេញជា ១៦ ខេត្ត គឺ៖

១ – ខេត្តកណ្ដាល

២ – ខេត្តកំពង់ស្ពឺ

៣ – ខេត្តតាកែវ

៤ – ខេត្តកំពត

៥ – ខេត្តព្រៃវែង

៦ – ខេត្តស្វាយរៀង

៧ – ខេត្តកំពង់ចាម

៨ – ខេត្តក្រចេះ

៩ – ខេត្តស្ទឹងត្រែង

១០ – ខេត្តកំពង់ធំ

១១ – ខេត្តកំពង់ឆ្នាំង

១២ – ខេត្តពោធិ៍សាត់

១៣ - ខេត្តសៀមរាប

១៤ - ខេត្តបាត់ដំបង

១៥ - ខេត្តកោះកុង

១៦ - ខេត្តរតនៈគីរី ។

ខេត្តនិមួយៗ បានចែកចេញជាស្រុកតិច ឬ ច្រើនតាមបញ្ញត្តិរាជរដ្ឋាភិបាល ។ ស្រុកទាំងឡាយគឺ =

ស្រុកភ្នំពេញ - ស្រុកពញាឮ - ស្រុកខ្សាច់កណ្ដាល - ស្រុកមុខកំពូល - ស្រុកកៀនស្វាយ - ស្រុកល្វាឯម - ស្រុកកណ្ដាលស្ទឹង ស្រុកលើកដែក . ស្រុកស្អាង - ស្រុកកោះធំ - ស្រុកកំពង់សៀម - ស្រុកព្រៃឈរ - ស្រុកដើមព្រៃ - ស្រុកចំការលើ - ស្រុកកោះសូទិន ស្រុកត្បូងឃ្មុំ - ស្រុកក្រូចឆ្មារ - ស្រុកមេមត់ - ស្រុកស្ទឹងត្រង់ - ស្រុកស្រីសន្ធរ - ស្រុកកងមាស - ស្រុកកំពត - ស្រុកព្រៃនប់ - ស្រុកបន្ទាយមាស - ស្រុកកំពង់ត្រាច - ស្រុកកំពង់សោម - ស្រុកឈូក - ស្រុកកោះកុង - ស្រុកដំនាប់ - ស្រុកព្រៃវែង - ស្រុកកំចាយមារ - ស្រុកពារាំង - ស្រុកស៊ីធរកណ្ដាល - ស្រុកបាភ្នំ - ស្រុក

អាំងប៊ិញ - ស្រុកកំពង់ត្របែក - ស្រុកកញ្ជៀច - ស្រុកបរិបូណ៌ ស្រុកកំពង់លែង - ស្រុកកំពង់ត្រឡាច - ស្រុករលាប្អៀរ - ស្រុក តាំងផ្លោច - ស្រុកទ្រាំង - ស្រុកគិរីវង្ស - ស្រុកបាទី - ស្រុកសំរោង ស្រុកព្រៃកប្បាស - ស្រុកត្រាំកក់ - ស្រុករំដួល - ស្រុកស្វាយទាប ស្រុករមាសហែក - ស្រុកកំពង់ស្វាយ · ស្រុកសណ្ដាន់ - ស្រុក ព្រហ្មទេព - ស្រុកបារាយណ៍ - ស្រុកស្ទោង - ស្រុកសន្ទុក - ស្រុក សៀមរាប · ស្រុកពួក · ស្រុកសូទ្រនិគម - ស្រុកជីក្រែង - ស្រុក ក្រចេះ - ស្រុកសម្បូណ៌ - ស្រុកស្នួល · ស្រុកឆ្លូង . ស្រុកសំរោង ទង · ស្រុកគងពិសី - ស្រុកថ្ពង - ស្រុកភ្នំស្រួច - ស្រុកបាកាន - ស្រុកភ្នំក្រវាញ - ស្រុកក្រគរ - ស្រុកស្ទឹងត្រែង - ស្រុកវ៉ឺន·សែ - ស្រុកសៀមបូក-ស្រុកសៀមប៉ាង-ស្រុកឡូមផាត់-ស្រុកបាត់តំបង- ស្រុកមោងឫស្សី - ស្រុកទឹកជោរ - ស្រុកសិរីសោភ័ណ - ស្រុក មង្គលបុរី - តំបន់រដ្ឋបាលស្វាយចេក - តំបន់រដ្ឋបាលបាក់ព្រា - តំបន់រដ្ឋបាលល្វា ។

ស្រុកនិមួយ ៗ ចែកចេញជាច្រើនឃុំ ។ ឃុំចែកចេញ

ជាច្រើនភូមិទៀត ។

ពជធានីភ្នំពេញបែកចេញជាសង្កាត់, មានមេសង្កាត់ជាអ្នកត្រួតត្រា ។

# គំនូរបំព្រួញអំពីអង្គការរដ្ឋបាលនៃប្រទេសកម្ពុជា



ប្រជារាស្ត្រខ្មែរទាំង ៥ លាននាក់ ជាអ្នកត្រួតត្រា និងចាត់ចែងកិច្ចការរដ្ឋ តាមលទ្ធិប្រជាធិបតេយ្យ ។

## ប្រវត្តិនៃរដ្ឋធម្មនុញ្ញខ្មែរ

រដ្ឋធម្មនុញ្ញ គឺច្បាប់សំរាប់រដ្ឋ ។ ច្បាប់នេះប្រសូតចេញពី-រដ្ឋសភា ដែលមានអស់លោកតំណាងរាស្ត្រជាអ្នកតែង ។ ហេតុនេះរដ្ឋធម្មនុញ្ញជាច្បាប់របស់រដ្ឋប្រជាធិបតេយ្យ សម្រាប់បំរើលទ្ធិប្រជាធិបតេយ្យ (La démocratie) ។ ប្រទេសនិមួយៗ មានរដ្ឋធម្មនុញ្ញប្លែកៗអំពីគ្នា តាមភាគភូមិសាស្ត្រ, ប្រជាជននិងនយោបាយ ។

រដ្ឋធម្មនុញ្ញខ្មែរ បានបង្កើតឡើងដោយរដ្ឋសភាខ្មែរដែលមាន ឯកឧត្តមអៀវ-កើស ជាប្រធាន ក្នុងគ្រិស្តសករាជ ១៩៤៧ ក្នុងរដ្ឋកាលព្រះបាទសម្តេចព្រះនរោត្តមសីហ-នុវរ្ម័ន ។ ព្រះករុណាដែលទ្រង់ប្រកបនូវទសពិធរាជធម៌ ទ្រង់បានឡាយព្រះហស្តលេខា, ព្រះរាជទានដល់ប្រជារាស្ត្រខ្មែរនូវ

រដ្ឋធម្មនុញ្ញនេះ ក្នុងថ្ងៃទី ៦ ឧសភា ឆ្នាំ ១៩៤៧ ដើម្បីសេចក្តីសុខ-ចំរើនរបស់ជាតិនិងមាតុប្រទេស ។ តាំងពីមានរដ្ឋធម្មនុញ្ញមក , គណៈនិគមបាំង មិនសប្បាយចិត្តនឹងខ្មែរទេ ។ ប៉ុន្តែសព្វកិច្ចការក្នុងស្រុកបានលូតលាស់ជាលំដាប់ ។

លុះមកដល់ថ្ងៃទី ៦ ខែធ្នូ គ.ស. ១.៩៥៥ រដ្ឋសភាដែលមានអស់លោកតំណាងរាស្ត្រ សុទ្ធតែសមាជិកនៃចលនាសង្គមរាស្ត្រនិយម ហើយដែលមានឯកឧត្តមអ៊ុំ-ឈាង-ស៊ុនជាប្រធាន , បានកែប្រែនិងបន្ថែមមាត្រាខ្លះក្នុងរដ្ឋធម្មនុញ្ញនេះ ។ ព្រះករុណាសម្តេចព្រះនរោត្តមសុរាម្រឹត ព្រះមហាក្សត្រដ៏ជាទីគោរពរបស់យើង ទ្រង់បានឡាយព្រះហស្តលេខាលើព្រះរាជក្រមលេខ ៦៥ ន.ស. ចុះថ្ងៃទី ១៤ មករា គ.ស ១៩៥៦ ប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញដែលបានកែប្រែជាថ្មីនេះ ។

តាំងពីថ្ងៃដែលមានរដ្ឋធម្មនុញ្ញរហូតមក , រៀងរាល់ឆ្នាំ , ប្រជាជនខ្មែរបានធ្វើបុណ្យរំឭករដ្ឋធម្មនុញ្ញនៅថ្ងៃទី ៦ ខែឧសភា ។

ប្រជាជនខ្មែរម្នាក់ ៗ ពេញចិត្តនឹងរដ្ឋធម្មនុញ្ញនិងលទ្ធិប្រជា-

ធិបតេយ្យដ៏បរិសុទ្ធរបស់ខ្លួនយ៉ាងអនេក ។

## ការផ្លាស់ប្តូរកែប្រែថ្មី

រដ្ឋធម្មនុញ្ញបានប្រសូតចេញក្នុងសម័យ ដែលរដ្ឋសភាមានអស់លោកតំណាងរាស្ត្រភាគច្រើនជាសមាជិកនៃគណៈបក្សប្រជាធិបតេយ្យ ; ហើយក្នុងពេលនោះ ប្រមុខនៃរាជរដ្ឋាភិបាល គឺអ្នកអង្គម្ចាស់យុត្តិវង្ស ។

រដ្ឋធម្មនុញ្ញបានកែប្រែនឹងបន្ថែមមាត្រាថ្មីជាច្រើនទៀត ក្នុងសម័យដែលរដ្ឋសភាមានអស់លោកតំណាងរាស្ត្រ ជាសមាជិកនៃចលនាសង្គមរាស្ត្រនិយមទាំងអស់, ហើយប្រមុខនៃរាជរដ្ឋាភិបាលគឺ សម្តេចព្រះនរោត្តម-សីហនុ , ព្រះបិតាឯករាជ្យជាតិ ។

ការកែប្រែខ្លះនឹងការបន្ថែមមាត្រាខ្លះទៀតនេះ អនុលោមទៅតាមគោលបំណងរបស់ចលនាសង្គមរាស្ត្រនិយម ដែលនិយមលើករាស្ត្រជាធំបំផុត ។ បុព្វហេតុដែលនាំឲ្យមានការកែប្រែនេះ ព្រោះរដ្ឋធម្មនុញ្ញរបស់គណៈបក្សប្រជាធិបតេយ្យ មិនមាន

លក្ខណៈប្រជាធិបតេយ្យនឹងលក្ខណៈជាតិគ្រប់គ្រាន់ ។ ចលនាសង្គមរាស្ត្រនិយម (រដ្ឋសភា) បានកែប្រែនឹងបន្ថែមជាច្រើនមាត្រា ប៉ុន្តែគោលដែលសំខាន់នោះគឺ =

- ត្រូវយកអក្សរខ្មែរមកប្រើជាផ្លូវការ ។
- ត្រូវឲ្យស្ត្រីនឹងបុរសមានសមភាព អាចធ្វើអ្វីបានដូចគ្នា។
- បង្កើតឲ្យមានសភាប្រជារាស្ត្រ ដើម្បីត្រួតត្រាសកម្មភាពរបស់រាជការសាធារណៈ បានជិតដល់ជាងមុន ។
- ត្រូវការនយោបាយអព្យាក្រិតនឹងសន្តិភាព ។
- បង្កើតឲ្យមានសមាជជាតិ ដែលជាស្ថាប័ន នៃមូលដ្ឋានប្រជាធិបតេយ្យរបស់ខ្មែរបច្ចុប្បន្ន ។ ទីដៅរបស់សមាជ គឺជាក់ចលនានឹងសកម្មភាពទាំងឡាយរបស់អ្នកតំណាងរាស្ត្រ, របស់សមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ឲ្យនៅក្រោមការត្រួតត្រារបស់ប្រជាជាតិកុង ១ ធមាសម្តង ។

•

# សញ្ញាណជាសារវ័ន្តនៃរដ្ឋធម្មនុញ្ញ

ប្រទេសកម្ពុជាមានព្រះមហាក្សត្រសោយរាជ្យ ។

រដ្ឋសភាខ្មែរជាអ្នកប្រើអំណាចនីតិបញ្ញត្តិក្នុងព្រះបរមនាមនៃព្រះមហាក្សត្រ ។

គណៈរដ្ឋមន្ត្រីខ្មែរជាអ្នកប្រើអំណាចនីតិប្រតិបត្តិក្នុងព្រះបរមនាមនៃព្រះមហាក្សត្រ ។

សាលាជំនុំជំរះក្តីគ្រប់ជាន់គ្រប់ថ្នាក់ ជាអ្នកប្រើអំណាចតុលាការក្នុងព្រះបរមនាមនៃព្រះមហាក្សត្រ ។ ខេមរជនមិនត្រូវនិរទេសពីដែនខ្មែរបានឡើយ ។ ខេមរជនស្រីប្រុសមានសមភាពស្មើគ្នា មានសេរីភាពក្នុងជំនឿ, ក្នុងការនិយាយសរសេរ បោះពុម្ព និងការផ្សាយដល់មហាជន កុំឲ្យតែប្រើសិទ្ធិនេះ ដោយរំលោភលើស្មារតីរដ្ឋធម្មនុញ្ញ ។

ខេមរជនទាំងពួងមានសិទ្ធិរួបរួមគ្នា ជាសមាគមដោយសេរី កុំឲ្យតែសមាគមនោះធ្វើឲ្យខូច ឬញុំាំងឲ្យខូចសេរីភាពទាំងឡាយ

ដែលរដ្ឋធម្មនុញ្ញបានធានាអះអាងឲ្យមាន ។ ខេមរជនមានសេរីភាពក្នុងការប្រជុំ ។ ទីលំនៅរបស់ខេមរជនមិនត្រូវនរណាចូលទៅរុករកដោយឥតច្បាប់បញ្ញត្តិបានឡើយ ។

សំបុត្រដែលផ្ញើទៅវិញទៅមករកគ្នា មិនត្រូវនរណាបើកមើលបានឡើយ វៀរលែងតែមានច្បាប់អនុញ្ញាត ដោយដាក់ស្តែងជាបណ្តោះអាសន្ន ។

អ្វីដែលច្បាប់មិនបង្គាប់ឲ្យធ្វើទេ ជនណាក៏ដោយមិនត្រូវគេបង្ខំឲ្យធ្វើបានឡើយ ។

## សម្បជញ្ញៈនិងឯកភាពនៃប្រជាជាតិ

ប្រជាជាតិខ្មែររស់នៅលើសង្គមមួយជាមួយគ្នា ។ សង្គមជាតិប្រៀបដូចជាទូក១ ដែលកំពុងបើកបរកណ្ដាលសាគរ ។ ប្រជាជាតិទុកដូចជាអ្នកជិះទូកនោះ ។ បើទូកនោះធ្លុះធ្លាយចូលទឹក, អ្នកនៅក្នុងទូកមិនរួបរួមគ្នាជួយចុកកន្លែងដែលធ្លាយនោះឲ្យជិតទេ , ម្នាក់ៗគិតតែផលប្រយោជន៍រៀងៗខ្លួន · អ្នកខ្លះរេបសំពាយ, អ្នកខ្លះសំពះទេពតា អ្នកខ្លះយំបន់ស្រន់, ទូកនោះចូលទឹកកាន់តែច្រើនឡើងៗ ហើយលិចទៅ ។ ទ្រព្យសម្បត្តិក៏ដូចជាអាយុជីវិតទាំងអស់របស់មនុស្សត្រូវអន្តរាយទៅហោង ។ ផ្ទុយមកវិញ, បើមនុស្សទាំងអស់មានសតិសម្បជញ្ញៈរួបរួមសាមគ្គីគ្នា ជួយចុកជួយញាត់កន្លែងដែលធ្លាយនោះឲ្យជិតទៅ ទូកនោះមុខជាទៅដល់ត្រើយ ។ ទ្រព្យសម្បត្តិក៏ដូចជាអាយុជីវិតមនុស្ស បានគង់វង្សបរិបូណ៌ ។ រឿងរ៉ាវរបស់ទូកយ៉ាងណា រឿងរ៉ាវរបស់សង្គមក៏យ៉ាងនោះដែរ ។ ហេតុនេះហើយ បានជាប្រជាជាតិត្រូវមានសតិសម្បជញ្ញៈភ្ញាក់

ព្រួតរួបរួមគ្នាជាឯកភាព  នៅលើស្មារតីកសាងជាតិឲ្យបានចំរើនជឿនលឿនទន់ក្តីស្មាន ។

## បំរើរាជបល្ល័ង្ក-ប្រជាជាតិនិងប្រជាជន

ប្រទេសខ្មែរមានព្រះមហាក្សត្រសោយរាជ្យ  តាំងពីបុរាណកាលរហូតមកដល់បច្ចុប្បន្ននេះ ។  ព្រះរាជបល្ល័ង្កជាម្លប់របស់ប្រជាជាតិខ្មែរ- ជានិមិត្តរូបនៃសាមគ្គីភាពរបស់ខ្មែរ ។  សម្តេចព្រះនរោត្តមសីហនុ  ជាស្ថាបនករដ៏ឆ្នើមនៃនយោបាយឯករាជ្យ, ឯកភាព, អព្យាក្រិតនិងសន្តិភាព ។

ប្រជាជាតិខ្មែរស្មោះសរនឹងនយោបាយសន្តិភាព - អព្យាក្រិតនេះ បានរួបរួមគ្នាដង្ហែតាមក្រោយព្រះអង្គ ដើម្បីបំរើព្រះរាជបល្ល័ង្កដែលជានិមិត្តរូបនៃប្រជាជាតិខ្មែរទាំងមូល ។

## លក្ខណៈគោល ៥ ១ ចិន - ឥណ្ឌៀ

លោកនាយកជូ - អេនឡាយ  និងលោកនាយកនេរូ  បាន

បង្កើតលក្ខណៈគោល ៥ ខ ចិន-ឥណ្ឌៀនេះ ដែលជាមាគ៌ានយោបាយក្រៅប្រទេសមួយដ៏មានខ្លឹមសារមហាប្រសើរ ។ ប្រទេសជាច្រើនដែលនិយម សេរីភាព - អធិបតេយ្យ - ឯករាជ្យ - សន្តិសុខនឹងសន្តិភាព បានប្រតិបត្តិលក្ខណៈគោល ៥ ខ ចិន ឥណ្ឌៀនេះ ។ ជាពិសេស , ចំពោះប្រទេសកម្ពុជាយើង នឹងប្រទេសឯទៀតក្នុងទ្វីបអាហ្វ្រិក - អាស៊ី ។ សហភាពសូវៀតបានប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនខ្ជូរលក្ខណៈគោលនេះ ។ ពួកចក្រពត្តិ ដែលមានសហរដ្ឋអាមេរិកជាមេដឹកនាំ ឥតគោរពលក្ខណៈគោលដ៏សំខាន់នេះទេ ។

លក្ខណៈគោលដ៏វិសេសវិសាលទាំង ៥ ខ នេះគឺ =

១ – គោរពទៅវិញទៅមកនូវអធិបតីភាពរបស់រដ្ឋរៀងខ្លួន ។

២ – មិនរុករានរំលោភលើគ្នា ។

៣ – មិនចូលជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋរៀងខ្លួន ។

៤ – ចងនឹងពង្រីកការទាក់ទងដ៏ជិតស្និទ្ធ ជាមួយរដ្ឋទាំងអស់តាមមូលដ្ឋានស្មើមុខគ្នា ដោយអនុលោមតាមផលប្រយោជន៍រៀងប្រទេស ។

៥ - រស់នៅជាមួយគ្នាដោយសុខសាន្ត ។

## លក្ខណៈគោល ១០ ខ បាន់-ឌុង

លក្ខណ៍គោល ១០ ខ បាន់-ឌុង ឬ កិច្ចការពារដោយរួបរួមគ្នា ដែលអនុលោមទៅតាមធម្មនុញ្ញនៃសហប្រជាជាតិ ។

១ – គោរពទៅវិញទៅមកនូវអធិបតេយ្យរបស់រដ្ឋរៀងខ្លួន ។

២ – មិនរុករានរំលោភលើគ្នា ។

៣ – មិនចូលជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋរៀងខ្លួន

៤ – បងនឹងពង្រីកការទាក់ទងដ៏ជិតស្និទ្ធជាមួយរដ្ឋទាំងអស់ តាមមូលដ្ឋានស្មើមុខគ្នា ដោយអនុលោមតាមផលប្រយោជន៍រៀងប្រទេស ។

៥ – រស់នៅជាមួយគ្នាដោយសុខសាន្ត ។

៦ – មិនឲ្យមហាអំណាចណាមួយ យកការរៀបចំការពាររួមទៅប្រើជាប្រយោជន៍ផ្ទាល់ពិសេសដោយឡែក ។ ពល់ ប្រទេសមិនត្រូវសង្កត់សង្កិនលើស្រុកណាមួយ ទុកជារបៀប

សន្ធិសន្តីទនោះ មានរូបភាពយ៉ាងណាក៏ដោយ ។

៧ - មិនត្រូវមានការគម្រាមបុករុកបំផ្លាញផែនដី ឬបង្ខិចឯករាជ្យនយោបាយរបស់ស្រុកឯទៀត ៗ ។

៨ - សម្រុះសម្រួលការទំនាស់ទាស់ទែងអន្តរជាតិ តាមសន្តិវិធីដូចជាការជជែកផ្សះផ្សា ការបញ្ចុះសម្រុះគ្នា ឬមធ្យោបាយផ្សេង ៗ ទៀត ដែលមានកំណត់ទុកក្នុងធម្មនុញ្ញរបស់សហប្រជាជាតិ ។

៩ - បង្កើតស្មារតីប្រួប្រួមក្នុងផលប្រយោជន៍ទៅវិញទៅមក ។

១០- គោរពដល់យុត្តិធម៌ និងការៈកិច្ចរបស់អន្តរជាតិ ។

លក្ខណ៍ការ ១០ „ ១ " នៃសន្និសីទអាស៊ី - អាហ្វ្រិកនាក្រុងបាន់ឌុង ជាមូលដ្ឋានរឹងប៉ឹងជាក់លាក់នៃមិត្តភាពនិងសាមគ្គីភាពរវាងប្រទេសខ្មែរយើងនិងបណ្ដាប្រទេសនៅអាស៊ី - អាហ្វ្រិក ។

សម្ដេចព្រះនរោត្តម - សីហនុ, ព្រះបិតាឯករាជ្យនៃជាតិយើង ទ្រង់បានទៅរួមប្រជុំក្នុងសន្និសីទនេះ នាក្រុងបាន់ - ឌុង, ប្រទេសឥណ្ឌូនេស៊ី ។

# អំពីអង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ ជាសភារបស់មនុស្សជាតិក្នុងពិភពលោក ។ អង្គការនេះមានទីតាត់ការធំនៅឯក្រុងញូវ-យ៉ក (សហរដ្ឋអាមេរិក) ។

អង្គការនេះមានបំណងស្វែងរកជូនប្រជាជាតិទាំងឡាយ នូវអធិបតេយ្យភាព-សេរីភាព-សមភាព-ភាតរៈភាព-សន្តិសុខ សន្តិភាព-វឌ្ឍនភាព ។

ប្រទេសទាំងឡាយណាដែលមានឯករាជ្យបរិបូណ៌អាចចូលបានជាសមាជិកនៃសភាដ៏ខ្ពស់នេះ ។ កម្ពុជាយើងបានចូលជាសមាជិកនៅថ្ងៃទី ១៤ ឆ្នាំ ១៩៥៥ ។ ប៉ុន្តែប្រទេសចិនប្រជាមានិត ដែលជាមហាប្រទេសសង្គមនិយមមួយ មានពលរដ្ឋប្រាំមួយរយហាសិបលាន (៦៥០.០០០.០០០) នាក់ ពុំទាន់បានចូលជាសមាជិកក្នុងអង្គការនេះនៅឡើយទេ ព្រោះពួកចក្រពត្តិ ហើយជាពិសេសគឺអាមេរិកកាំង ដែលជាអ្នកមានអំណាចក្នុងច្បាប់

(Véto) បានប្រឆាំងមិនព្រមឲ្យចូល ។ ប្រទេសខ្មែរយើង ដែលមានសម្តេចព្រះបិតាឯករាជ្យទ្រង់យាងទៅប្រជុំក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីឆ្នាំ ១៩៥៩ ទ្រង់បានខំខ្នះខ្នែងទាមទារឲ្យមហាមិត្តចិនបានចូលមកក្នុងអង្គការនេះ ។ មានប្រទេសជាច្រើនអបអរសាទរចំពោះព្រះរាជយោបល់ដ៏ថ្លៃថ្លារបស់សម្តេច ។

អង្គការសហប្រជាជាតិ មានច្រើនក្រុមដូចតទៅនេះ៖

១ – អង្គការអន្តរជាតិខាងការងារ (អ.អ.ក.) ។

២ – អង្គការសហប្រជាជាតិសម្រាប់ការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌ (អ.ស.ប.អ.វ.វ.) ។

៣– អង្គការពិភពលោកខាងសុខាភិបាល (អ. ព. ស.) ។

៤ – អង្គការសហប្រជាជាតិសម្រាប់ស្បៀងអាហារ និងកសិកម្ម (អ. ស. ប. ស. ក. ) ។

៥ – សហភាពប្រៃសណីយ៍ពិភពលោក (ស. ប. ព.) ។

៦ – ក្រុមប្រឹក្សាទិរភ័យ (ក. ប. ន. ភ. ) ។

## រដ្ឋទូតបរទេសអមព្រះរាជាណាចក្រកម្ពុជា

ចាប់តាំងពីថ្ងៃ ដែលយើងបានប្រកាសឯករាជ្យបរិបូណ៌ , ប្រទេសជាច្រើនក្នុងសកលលោក បានផ្ញើសារទូរលេខមកទទួលស្គាល់ប្រទេសយើងជាផ្លូវការ ។ អង្គការសហប្រជាជាតិក៏បានបើកទ្វារឲ្យយើងចូលជាសមាជិកពេញលក្ខណៈដែរ ។

ប្រទេសយើងប្រកាន់យកមាគ៌ាសន្តិភាព នឹងអព្យាក្រឹត្យជានយោបាយក្រៅប្រទេស ។ នយោបាយនេះនាំឲ្យយើងមានមិត្តច្រើន ។ រដ្ឋទូតបរទេសដែលមកនៅអមរាជបល្ល័ង្កខ្មែរ មានគ្រប់ពណ៌សម្បុរនយោបាយទាំងអស់ ។ ខាងផ្នែកសេរីអាមេ-រិកកាំង យើងសង្កេតឃើញៈ រដ្ឋទូតអាមេរិកកាំង អគ្គរាជទូតអង់គ្លេស- រដ្ឋទូតបារាំង- អគ្គរាជទូតថៃឡង់ដ៍ ។ល។

ខាងផ្នែកលោកសង្គមនិយម យើងសង្កេតឃើញៈ រដ្ឋទូតនៃសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត-រដ្ឋទូតចិនប្រជាមា-និត- រដ្ឋទូតឆេកូស្លូវ៉ាគី- រដ្ឋទូតប៉ូឡូញ ។ល។ ខាងផ្នែកប្រទេស

អព្យាក្រឹត្យ មានរដ្ឋទូតឥណ្ឌា- រដ្ឋទូតឥណ្ឌូណេស៊ី- រដ្ឋទូតអារ៉ាប់រួម- រដ្ឋទូតភូមា ។ល។

ក្រៅអំពីស្ថានឯកអគ្គរាជទូត នឹងរដ្ឋទូត, យើងសង្កេតឃើញ ស្ថានអ្នកតំណាងសាធារណរដ្ឋវៀតណាមខាងត្បូង ហើយនឹងកុងស៊ុលជាច្រើនទៀត ។

## ឯកអគ្គរាជទូតខ្មែរនៅឯបរទេស

ខ្មែរយើងបានធ្វើការទាក់ទងខាងផ្លូវទូតជាមួយបរទេស ទាំង ៣ ផ្នែក គឺផ្នែកលោកសេរី - ផ្នែកលោកសង្គមនិយម នឹងផ្នែកលោកអព្យាក្រិត ។

ឯកឧត្តមនង់-គីម-នី ជាឯកអគ្គរាជទូតខ្មែរ នៅក្រុងវ៉ា-ស៊ីនតោន អមរដ្ឋាភិបាលអាមេរិកកាំង ដែលជាមេក្លាងនៃលោកសេរី ។ ឯកឧត្តមឃឹម-ទិត ជាឯកអគ្គរាជទូតខ្មែរនៅក្រុងម៉ូស្គូ អមរដ្ឋាភិបាលសូវៀត ដែលជាមេក្លាងនៃលោកសង្គមនិយម ។ ឯកឧត្តម-ក៉ា-ម៉ែល ជាឯកអគ្គរាជទូតខ្មែរ នៅ

ក្រុងញូវ-ដែល-ល្ហី អមរដ្ឋាភិបាលឥណ្ឌៀ , ជារៀមច្បងរបស់ បណ្ដាប្រទេសអព្យាក្រិត ។

សព្វថ្ងៃនេះ , ខ្មែរយើង មានស្ថានទូតតាំងនៅឯបរទេស ជាច្រើន ក៏ដូចជាស្ថានទូតបរទេស មកតាំងនៅក្នុងប្រទេស យើងអញ្ចឹងដែរ ។

---

## មាគ៌ារបស់សន្តិភាព

មនុស្សក្នុងលោករមែងស្អប់ខ្ពើមសង្គ្រាម ហើយស្រេក ទាមទារកសន្តិភាព ។ ប្រជាជនខ្មែរជឿជាក់ថា : មានតែ សន្តិភាពមួយយ៉ាងទេ ដែលអាចធ្វើឲ្យខ្មែរ នឹងប្រជាជនមហាជន មានជីវភាពសម្បូណ៌សប្បាយ ។ ហេតុនេះ , មាគ៌ានយោបាយ របស់ខ្មែរ ដែលដឹកនាំដោយសម្ដេចព្រះនរោត្តម - សីហនុ ជា នយោបាយឯកពជ្យនឹងអព្យាក្រិត្យ ។ នយោបាយអព្យាក្រិតនេះ ហើយ ដែលជាមាគ៌ានៃសន្តិភាព ។

= ចប់ =

## ផ្សាយចេញពីបណ្ណាគារខ្មែរ-សម័យ

### កំពង់ចាម

| | | |
|---|---|---|
| – ពង្សាវតារប្រទេសកម្ពុជាសង្ខេប | (ម៉េង-ដិន) | ១៨'០ |
| – ក្បួនតព្វគ្គចំណោទលើលេខទាំងបួន | (ឈាង-គីម-ឈាន) | ១៥.០០ |
| – ក្បួនតព្វគ្គចំណោទដោទឆ្លើយទេមរភាសា | ,, | ២០,០០ |
| – ប្រវត្តិអក្សរសាស្ត្រខ្មែរ | (គីម-សែត) | ២៥.០០ |
| – វិធីចងបទសម្ពន្ធ | (គីម-សែត) | ១៥.០០ |
| – ការតែងសេចក្តីខ្មែរ | ( ,, ) | ២៥.០០ |
| – ល្បើកឡាហ្វុងតែន | ( ,, ) | ១៧,០០ |
| – សង្គមវិជ្ជា | ( ,, ) | ២០,០០ |
| – សិក្សាអក្សរសាស្ត្ររឿងរាមកេរ្តិ៍ | (ឌិម-ណាគ្រ៊ី) | ២៨.០០ |
| – មរណមាតា | (តាមច្បាប់ស៊ីកវិត) | ២០,០០ |
| – ធនញ្ជ័យ | ,, | ១២៦.០០ |
| – សព្វសិទ្ធិ | ,, | ២០.០០ |
| – ពុញ្ញសារៈសិរីសា | ,, | ១៥.០០ |
| – ល្បើកបឋក | ,, | ១០.០០ |
| – មាយាស្ត្រី | ,, | ៣.០០ |
| – សុបិន | ,, | ៣.០០ |
| – មាយើង | ,, | ៣,០០ |
| – និងរឿងព្រេងផ្សេងៗ ព្រមទាំងច្បាប់បុរាណ | ,, | |

រោងពុម្ពស៊ី          តម្លៃ ២០ ៛ ០០